00401941

ERN/N: D 240

**នៅចំពោះមុខការិយាល័យសហចៅក្រមស៊ើបអង្កេត**
**អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**

| ឯកសារបានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម<br>CERTIFIED COPY/COPIE CERTIFIÉE CONFORME |
|---|
| ថ្ងៃ ខែ ឆ្នាំ នៃការបញ្ជាក់ (Certified Date /Date de certification): 28 / 01 / 2010 |
| មន្ត្រីទទួលបន្ទុកសំណុំរឿង /Case File Officer/L'agent chargé du dossier: Ratanak |

**ព័ត៌មានពិស្តារអំពីការដាក់ឯកសារ**

សំណុំរឿងលេខ: ០០២/១៩-០៩-២០០៧-អ.វ.ត.ក-ក.ស.ច.ស

ភាគីដាក់ឯកសារ: សហមេធាវីរបស់លោក អៀង សារី

ដាក់ជូន: សហចៅក្រមស៊ើបអង្កេត

ភាសាដើម: អង់គ្លេស

កាលបរិច្ឆេទឯកសារ: ថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ២០០៩

**ចំណាត់ថ្នាក់ឯកសារ**

ចំណាត់ថ្នាក់ឯកសារ ស្នើឡើងដោយភាគីដាក់ឯកសារ: សាធារណៈ

ចំណាត់ថ្នាក់ឯកសារដោយ កសចស ឬ អង្គជំនុំជម្រះ: សម្ងាត់ CONFIDENTIAL CONFIDENTIEL 16/11/2009

ពិនិត្យឡើងវិញចំពោះឯកសារចំណាត់ថ្នាក់បណ្ដោះអាសន្ន: សាធារណៈ PUBLIC 28/01/2010

ឈ្មោះមន្ត្រីកត់ត្រា:

ហត្ថលេខា:

---

**សំណើរបស់លោក អៀង សារី ប្រឆាំងទៅនឹងលទ្ធភាពនៃការយកច្បាប់ស្តីពី**
**ឧក្រិដ្ឋកម្មប្រល័យពូជសាសន៍មកអនុវត្តនៅ អ.វ.ត.ក**

---

ដាក់ដោយ៖

**សហមេធាវីរបស់លោក អៀង សារី**

លោក អាង ឧត្តម

លោក Michael G. KARNAVAS

ផ្ញើជូន៖

**សហចៅក្រមស៊ើបអង្កេត**

ចៅក្រម យូ ប៊ុនឡេង

ចៅក្រម Marcel LEMONDE

**សហព្រះរាជអាជ្ញា**

លោកស្រី ជា លាង

លោក William SMITH

| ឯកសារទទួល<br>DOCUMENT RECEIVED/DOCUMENT REÇU |
|---|
| ថ្ងៃ ខែ ឆ្នាំ (Date of receipt/Date de reception): 30 / 10 / 2009 |
| ម៉ោង (Time/Heure): 15 : 15 |
| មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: Uch Arun |

លោក អៀង សារី តាមរយៈសហមេធាវីរបស់គាត់ (“មេធាវីការពារក្តី”) សូមជំទាស់ទៅនឹងការយកច្បាប់ស្តីពីឧក្រិដ្ឋកម្មប្រល័យពូជសាសន៍មកអនុវត្តនៅ អ.វ.ត.ក[1]។ ក.ស.ច.ស ទើបបានទទួលសំណើប្រហាក់ប្រហែលគ្នានេះទាក់ទងនឹងបញ្ហាយុត្តាធិការ[2]។ សំណើនេះមានភាពចាំបាច់ដោយសារ ច្បាប់ស្តីពីឧក្រិដ្ឋកម្មប្រល័យពូជសាសន៍គឺមិនអាចអនុវត្តនៅ អ.វ.ត.ក បានឡើយព្រោះវាផ្ទុយនឹងគោលការណ៍ *“គ្មានបទល្មើសបើគ្មានច្បាប់ចែង”* ដោយហេតុថា **(ក)** ឧក្រិដ្ឋកម្មនេះពុំត្រូវបានគេចាត់ទុកថាជាបទល្មើសក្រោមច្បាប់ជាតិទេ។ ឧក្រិដ្ឋកម្មនេះមិនមានចែងនៅក្នុងក្រមព្រហ្មទណ្ឌកម្ពុជាឆ្នាំ ១៩៥៦ (“ក្រមព្រហ្មទណ្ឌឆ្នាំ ១៩៥៦”) និងនៅក្នុងកិច្ចព្រមព្រៀងទេ[3] ហើយច្បាប់ស្តីពីការបង្កើត អ.វ.ត.ក[4] ពុំអាចបង្កើតច្បាប់សារធាតុដែលត្រូវយកមកអនុវត្តជាប្រតិសកម្មបានឡើយ។ ហើយ **(ខ)** ច្បាប់ព្រហ្មទណ្ឌអន្តរជាតិពុំអាចត្រូវបានគេយកមកអនុវត្តដោយផ្ទាល់នៅកម្ពុជាបានឡើយ។ កម្ពុជាគ្មានច្បាប់ដើម្បីអនុម័តអនុសញ្ញាស្តីពីការបង្ការ និងការផ្តន្ទាទោសឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ឆ្នាំ ១៩៤៨ ទេ (“អនុសញ្ញាប្រល័យពូជសាសន៍”) ហើយច្បាប់ទំនៀមទម្លាប់អន្តរជាតិ និង *វិធានអាជ្ញាបញ្ញា* (*jus cogens*) ដែលចាត់ទុកអំពើប្រល័យពូជសាសន៍ថាជាបទល្មើសនោះពុំអាចត្រូវបានគេយកមកអនុវត្តផ្ទាល់នៅកម្ពុជាបានឡើយ។ ថ្វីបើ ក.ស.ច.ស សម្រេចថាខ្លួនមានយុត្តាធិការទៅលើឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ និងថ្វីបើមានទឡ្ហីករណ៍ផ្ទុយពីនេះក៏ពិតមែន ប៉ុន្តែមេធាវីការពារក្តីសូមអះអាងថាគេពុំអាចចោទលោក អៀង សារី ពីបទប្រល័យពូជសាសន៍បានទៀតឡើយដោយហេតុថាការចោទប្រកាន់ដូច្នេះ គឺជាការរំលោភបទបញ្ញត្តិនៃព្រះរាជក្រិត្យលើកលែងទោសឲ្យលោក អៀង សារី រួចផុតពីការចោទប្រកាន់អំពីអំពើប្រល័យពូជសាសន៍ និងរំលោភគោលការណ៍ *គ្មានការកាត់*

---

[1] *សូមមើល* ការចេញផ្សាយសារព័ត៌មាន សេចក្តីថ្លែងការណ៍របស់សហព្រះរាជអាជ្ញា ចុះថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០០៧ (គូសបញ្ជាក់បន្ថែម)។ “ការចោទប្រកាន់អង្គហេតុក្នុងសេចក្តីសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ កំណត់បទឧក្រិដ្ឋប្រឆាំងនឹងមនុស្សជាតិ <u>អំពើប្រល័យពូជសាសន៍</u> ការរំលោភធ្ងន់ធ្ងរនៃអនុសញ្ញាក្រុងហ្សឺណែវ មនុស្សឃាដ ការធ្វើទារុណកម្ម និង ការធ្វើទុក្ខបុកម្នេញខាងសាសនា។ ដូច្នេះ សហព្រះរាជអាជ្ញាបានស្នើទៅសហចៅក្រមស៊ើបអង្កេតឲ្យចោទប្រកាន់អ្នកទាំងឡាយណាដែលទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្មទាំងនេះ”។

[2] *សូមមើល រឿងក្តី អៀង សារី* សំណុំរឿងលេខ០០២/១៩-០៩-២០០៧-អ.វ.ត.ក-ក.ស.ច.ស ពាក្យស្នើសុំរបស់លោកអៀង សារី ប្រឆាំងនឹងការអនុវត្តនៅ អ.វ.ត.ក នូវទម្រង់នៃការទទួលខុសត្រូវខាងព្រហ្មទណ្ឌ ដែលគេហៅថា *សហកម្មឧក្រិដ្ឋកម្មរួម* ចុះថ្ងៃទី ២៨ ខែកក្កដា ឆ្នាំ២០០៨ ឯកសារ D97, ERN: 00208225-00208240 ។ *សូមមើល ផងដែរ* សេចក្តីសន្និដ្ឋានទាំងអស់ផ្សេងទៀត ទាក់ទងនឹង JCE ដែលបានដាក់នៅមុខ ក.ស.ច.ស ។

[3] កិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជាទាក់ទងនឹងការកាត់សេចក្តីនៅក្រោមច្បាប់កម្ពុជា នូវឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងនៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ (“កិច្ចព្រមព្រៀង”)។

[4] ច្បាប់ស្តីពីការបង្កើតឲ្យមានអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដើម្បីកាត់សេចក្តីឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងនៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ (“ច្បាប់ស្តីពីការបង្កើត អវតក”)។

*ទោសពីរដងចំពោះបទល្មើសតែមួយ (ne bis in idem)*[5]។

## I. ច្បាប់ជាធរមាន

### ក. បទបញ្ញត្តិនៃកិច្ចព្រមព្រៀង និងច្បាប់ស្តីពីការបង្កើតឲ្យមាន អ.វ.ត.ក ទាក់ទងនឹងបញ្ហាយុត្តាធិការ

១. មាត្រា ១ នៃកិច្ចព្រមព្រៀងចែងថា៖

> គោលបំណងរបស់កិច្ចព្រមព្រៀងនេះគឺកំណត់អំពីកិច្ចសហប្រតិបត្តិការ រវាងអង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជា ដើម្បីកាត់សេចក្តីមេដឹកនាំជាន់ខ្ពស់កម្ពុជាប្រជាធិបតេយ្យ និងជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុតចំពោះឧក្រិដ្ឋកម្ម និងការរំលោភយ៉ាងធ្ងន់ធ្ងរទៅលើច្បាប់ព្រហ្មទណ្ឌកម្ពុជា ការរំលោភទៅលើច្បាប់មនុស្សធម៌ និងទម្លាប់អន្តរជាតិ ព្រមទាំងការរំលោភលើអនុសញ្ញាអន្តរជាតិ ដែលប្រទេសកម្ពុជាទទួលស្គាល់ ហើយដែលបានប្រព្រឹត្តក្នុងអំឡុងថ្ងៃ១៧ មេសា ១៩៧៥ ដល់ថ្ងៃ០៦ មករា ១៩៧៩។ ក្នុងចំណោមប្រការផ្សេងៗទៀត កិច្ចព្រមព្រៀងនេះផ្តល់មូលដ្ឋានគតិយុត្តិ គោលការណ៍ និងបែបបទសម្រាប់កិច្ចសហប្រតិបត្តិការនេះ។

២. មាត្រា ២ (១) នៃកិច្ចព្រមព្រៀងចែងថា៖

> កិច្ចព្រមព្រៀងនេះទទួលស្គាល់ថាអង្គជំនុំជម្រះវិសាមញ្ញមានយុត្តាធិការលើរឿងក្តី ដូចដែលបានចែងក្នុង "ច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាដើម្បីកាត់សេចក្តីឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តឡើងក្នុងរយៈកាលកម្ពុជាប្រជាធិបតេយ្យ"... ដូចដែលបានអនុម័ត និងធ្វើវិសោធនកម្មដោយអង្គនីតិប្បញ្ញត្តិកម្ពុជានៅក្រោមរដ្ឋធម្មនុញ្ញកម្ពុជា។ កិច្ចព្រមព្រៀងនេះទទួលស្គាល់ផងដែរថាអង្គជំនុំជម្រះវិសាមញ្ញមានយុត្តាធិការលើរូបបុគ្គលជាមេដឹកនាំជាន់ខ្ពស់កម្ពុជាប្រជាធិបតេយ្យ និងជនទាំងឡាយដែលទទួលខុស

---

[5] *សូមមើល រឿងក្តី អៀង សារី* សំណុំរឿងលេខ០០២/១៩-០៩-២០០៧-អ.វ.ត.ក-ក.ស.ច.ស (អ.ប.ជ០៣), សារណារបស់លោក អៀង សារី អនុលោមតាម *សេចក្តីសម្រេចអំពីសំណើជាបន្ទាន់ របស់សហមេធាវី សុំការពន្យាពេលសមស្របក្នុងការដាក់សារណាជំទាស់នឹងបញ្ហាយុត្តាធិការ ចុះថ្ងៃទី៧ ខែមេសា ឆ្នាំ២០០៨, ឯកសារ* C22/I/26, ERN: 00177265-00177280។ *សូមមើលផងដែរ រឿងក្តី អៀង សារី* សំណុំរឿងលេខ០០២/១៩-០៩-២០០៧-អ.វ.ត.ក-ក.ស.ច.ស (អ.ប.ជ០៣), សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចឃុំខ្លួនជនត្រូវចោទ អៀង សារី បណ្តោះអាសន្ន ចុះថ្ងៃទី១៧ ខែតុលា ឆ្នាំ២០០៨ កថាខណ្ឌ ៤១-៦៣, ឯកសារ C22/I/74, ERN: 00232976-00233004, ដែលអង្គបុរេជំនុំជម្រះលើកឡើងថា ខ្លួនមិនអាចកំណត់បញ្ហាទាំងនេះនៅពេលនោះបានទេ។

ត្រូវខ្ពស់បំផុតចំពោះឧក្រិដ្ឋកម្មដែលបានចែងក្នុងមាត្រា ១ នៃកិច្ចព្រមព្រៀង។

៣. មាត្រា ៩ នៃកិច្ចព្រមព្រៀងមួយផ្នែកបានចែងថា៖

យុត្តាធិការលើរឿងក្តីរបស់អង្គជំនុំជម្រះវិសាមញ្ញ រួមមានឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ ដូចដែលបានកំណត់ក្នុងអនុសញ្ញាឆ្នាំ១៩៤៨ ស្តីការបង្ការនិងការផ្តន្ទាទោសឧក្រិដ្ឋកម្មប្រល័យពូជសាសន៍...។

៤. មាត្រា ១ នៃច្បាប់ស្តីពីការបង្កើតឱ្យមាន អ.វ.ត.ក ចែងថា៖

ច្បាប់នេះរៀបចំឡើងក្នុងគោលបំណងវិនិច្ឆ័យទោស មេដឹកនាំជាន់ខ្ពស់កម្ពុជាប្រជាធិបតេយ្យ និងជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុតចំពោះឧក្រិដ្ឋកម្ម និងការរំលោភយ៉ាងធ្ងន់ធ្ងរទៅលើច្បាប់ព្រហ្មទណ្ឌកម្ពុជា ការរំលោភទៅលើច្បាប់មនុស្សធម៌អន្តរជាតិ និងទម្លាប់អន្តរជាតិ ព្រមទាំងការរំលោភលើអនុសញ្ញាអន្តរជាតិដែលប្រទេសកម្ពុជាទទួលស្គាល់ ហើយដែលបានប្រព្រឹត្តក្នុងអំឡុងថ្ងៃ ១៧ មេសា ១៩៧៥ ដល់ថ្ងៃ ៦ មករា ១៩៧៩។

៥. មាត្រា ២ ថ្មីនៃច្បាប់ស្តីការបង្កើតឱ្យមាន អ.វ.ត.ក ចែងថា៖

ត្រូវបានបង្កើតឱ្យមានអង្គជំនុំជម្រះវិសាមញ្ញនៅក្នុងរចនាសម្ព័ន្ធតុលាការ ដែលមានស្រាប់ពោលគឺសាលាដំបូង សាលាឧទ្ធរណ៍ និងតុលាការកំពូល ដើម្បីជំនុំជម្រះមេដឹកនាំជាន់ខ្ពស់កម្ពុជាប្រជាធិបតេយ្យ និងជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុតចំពោះឧក្រិដ្ឋកម្ម និងការរំលោភយ៉ាងធ្ងន់ធ្ងរទៅលើច្បាប់កម្ពុជាដែលពាក់ព័ន្ធនឹងអំពើឧក្រិដ្ឋ ការរំលោភទៅលើច្បាប់មនុស្សធម៌អន្តរជាតិ និងទម្លាប់អន្តរជាតិ និងការរំលោភទៅលើអនុសញ្ញាអន្តរជាតិដែលប្រទេសកម្ពុជាទទួលស្គាល់ ហើយដែលបានប្រព្រឹត្តក្នុងអំឡុងថ្ងៃ ១៧ មេសា ១៩៧៥ ដល់ថ្ងៃ ៦ មករា ១៩៧៩។

៦. មាត្រា ៤ នៃច្បាប់ស្តីពីការបង្កើតឱ្យមាន អ.វ.ត.ក ចែងថា៖

អង្គជំនុំជម្រះវិសាមញ្ញមានអំណាចវិនិច្ឆ័យទោសជនសង្ស័យទាំងឡាយ ដែលបានប្រព្រឹត្តឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ដូចមានចែងក្នុងអនុសញ្ញាឆ្នាំ១៩៤៨ ស្តីពីការបង្ការ និងការផ្តន្ទាទោសចំពោះឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ ហើយដែលបានប្រព្រឹត្តក្នុងអំឡុងថ្ងៃ ១៧ ខែមេសា ឆ្នាំ១៩៧៥ ដល់ថ្ងៃទី៦ ខែមករា ឆ្នាំ១៩៧៩។ អំពើប្រល័យពូជសាសន៍ដែលគ្មានអាជ្ញាយុកាលគឺជាអំពើមួយក្នុងចំណោមអំពើដូចខាងក្រោម ហើយដែលបានប្រព្រឹត្តក្នុង

គោលបំណងបំផ្លិចបំផ្លាញទាំងស្រុង ឬមួយផ្នែកនៃក្រុមជាតិ ជាតិពន្ធុ ពូជសាសន៍ ឬសាសនាណាមួយដូចជា៖

- ការធ្វើមនុស្សឃាតទៅលើសមាជិកនៃក្រុម
- ការធ្វើឱ្យរបួសយ៉ាងធ្ងន់ធ្ងរដល់រូបរាងកាយ ឬសតិបញ្ញាសមាជិកនៃក្រុម
- ការធ្វើដោយចេតនាឱ្យក្រុមនេះ ទទួលរងនូវស្ថានភាពរស់នៅមួយដែលបានរៀបចំឡើងសម្រាប់បំផ្លិចបំផ្លាញរាងកាយទាំងស្រុង ឬមួយផ្នែក
- ការដាក់នូវវិធានការនានាដែលមានបំណងរារាំងមិនឱ្យមានការផ្តល់កំណើតទារក
- ការបញ្ជូនកុមារដោយបង្ខំ ពីក្រុមមួយទៅឱ្យក្រុមមួយផ្សេងទៀត។

បទល្មើសខាងក្រោមត្រូវផ្តន្ទាទោសដូចបទល្មើសខាងលើដែរ៖

- ការប៉ុនប៉ងប្រព្រឹត្តអំពើប្រល័យពូជសាសន៍
- ការសមគំនិតប្រព្រឹត្តអំពើប្រល័យពូជសាសន៍
- ការចូលរួមប្រព្រឹត្តអំពើប្រល័យពូជសាសន៍។

### ខ. គោលការណ៍ *គ្មានបទល្មើស បើគ្មានច្បាប់ចែង*

៧. គោលការណ៍ *គ្មានបទល្មើសបើគ្មានច្បាប់ចែង*[6] ចែងថា គ្មានជនណាម្នាក់ត្រូវបានគេចោទប្រកាន់ចំពោះអំពើមួយ លើកលែងតែអំពើនោះត្រូវបានកំណត់ក្នុងច្បាប់ថាជាបទល្មើសនាពេលដែលមានបទល្មើសនោះកើត និងមានច្បាប់ចែងថាអោយមានការផ្តន្ទាទោស។ គោលការណ៍នេះមានចែងនៅក្នុងសេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស និងកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិ

[6] ជាពិសេស គោលការណ៍ *គ្មានបទល្មើស បើគ្មានច្បាប់ចែង* (*nullum crimen sine lege*) នៅក្នុងប្រទេសប្រកាន់យកច្បាប់ស៊ីវិលឡូ គេកំណត់យកគោលការណ៍បួនគឺ៖ i) បទល្មើសព្រហ្មទណ្ឌអាចត្រូវបានកំណត់ តែក្នុងច្បាប់ជាលាយលក្ខណ៍អក្សរតែប៉ុណ្ណោះ ("*nullum crimen sine lege scripta*"); ii) បទល្មើសព្រហ្មទណ្ឌត្រូវកំណត់តាមរយៈច្បាប់ជាក់លាក់ ("*nullum crimen sine lege stricta*"); iii) បទល្មើសព្រហ្មទណ្ឌត្រូវកំណត់ចំពោះមុខច្បាប់ ("*nullum crimen sine proevia lege*"); និង iv) បទល្មើសព្រហ្មទណ្ឌមិនត្រូវបកស្រាយដោយភាពស្រដៀងគ្នានោះទេ។ ANTONIO CASESSE, INTERNATIONAL CRIMINAL LAW, ១៤១-៤២ (បោះពុម្ពដោយ Oxford University Press, ឆ្នាំ២០០៣) (ហៅកាត់ថា "CASESSE")។

នយោបាយ (“កតិកាសញ្ញា ICCCPR”) ដែល អ.វ.ត.ក ត្រូវគោរពតាមបទដ្ឋាននេះទាំងស្រុង[7]។

៨. មាត្រា ១១ (២) នៃសេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្សបញ្ជាក់អំពីគោលការណ៍នេះដែលមានសេចក្តីដូចតទៅ៖

គ្មានជនណាម្នាក់ត្រូវបានផ្តន្ទាទោសពីបទល្មើសព្រហ្មទណ្ឌដោយបានប្រព្រឹត្ត ឬភ្លាំងភ្លាត់ប្រព្រឹត្តដែលអំពើនេះមិនបានចែងក្នុងច្បាប់ជាតិ ឬអន្តរជាតិ។ មិនត្រូវផ្តន្ទាទោសឱ្យធ្ងន់ជាងទោសដែលបានកំណត់ឱ្យអនុវត្តក្នុងអំឡុងពេលបទល្មើសបានកើតឡើងឡើយ។

៩. មាត្រា ១៥ នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយចែងថា៖

១. គ្មានជនណាម្នាក់ត្រូវជាប់ពិរុទ្ធពីបទល្មើសព្រហ្មទណ្ឌចំពោះអំពើ ឬការខកខានណាមួយដែលមិនបានចាត់ជាបទល្មើសព្រហ្មទណ្ឌស្របតាមច្បាប់ជាតិ ឬច្បាប់អន្តរជាតិក្នុងខណៈពេលប្រព្រឹត្តនោះឡើយ។ ដូចគ្នានេះមិនត្រូវដាក់ទោសឱ្យធ្ងន់ជាងទោសដែលអនុវត្តក្នុងខណៈពេលប្រព្រឹត្តបទល្មើសឡើយ។ ប្រសិនបើក្រោយពីការប្រព្រឹត្តបទល្មើសហើយច្បាប់បានបញ្ញត្តិឱ្យមានការដាក់ទោសស្រាលជាងមុន ជនល្មើសត្រូវទទួលអត្ថប្រយោជន៍ពីការដាក់ទោសស្រាលជាងនេះ។

២. គ្មានបញ្ញត្តិណាមួយក្នុងមាត្រានេះប្រឆាំងនឹងការជំនុំជម្រះក្តី ឬការផ្តន្ទាទោសដល់ជនណាម្នាក់ចំពោះអំពើ ឬការខកខានណាមួយដែលជននោះបានប្រព្រឹត្តក្នុងខណៈពេលដែលអំពើ ឬការខកខាននោះជាបទល្មើសព្រហ្មទណ្ឌស្របតាមគោលការណ៍ទូទៅនៃច្បាប់

---

[7] យោងតាមមាត្រា៣១ នៃរដ្ឋធម្មនុញ្ញឆ្នាំ១៩៩៣ របស់ព្រះរាជាណាចក្រកម្ពុជា ដូចដែលត្រូវបានធ្វើវិសោធនកម្មនៅថ្ងៃទី៤ ខែមីនា ឆ្នាំ១៩៩៩ “[ព្រះ]រាជាណាចក្រកម្ពុជាទទួលស្គាល់ និងគោរពសិទ្ធិមនុស្ស ដូចមានចែងក្នុងធម្មនុញ្ញនៃអង្គការសហប្រជាជាតិ សេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស និង កតិកាសញ្ញាព្រមទាំងអនុសញ្ញាទាំងឡាយទាក់ទងនឹងសិទ្ធិមនុស្សសិទ្ធិនារី និងសិទ្ធិកុមារ។ (គូសបញ្ជាក់បន្ថែម)។ យោងតាមមាត្រា៣៣ថ្មី នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក “អង្គជំនុំជម្រះវិសាមញ្ញរបស់សាលាដំបូងត្រូវអនុវត្តន៍យុត្តាធិការរបស់ខ្លួនសមស្របតាមបទដ្ឋានយុត្តិធម៌អន្តរជាតិ ភាពត្រឹមត្រូវនឹងដំណើរការសមស្របនៃច្បាប់ដូចដែលបានចែងក្នុងមាត្រា១៤ និង១៥ នៃអនុសញ្ញាអន្តរជាតិឆ្នាំ១៩៦៦ ស្តីពីសិទ្ធិពលរដ្ឋ និងនយោបាយ”។ យោងតាមមាត្រា១៣(១) នៃកិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជាទាក់ទងនឹងការកាត់សេចក្តីនៅក្រោមច្បាប់កម្ពុជានូវឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងនៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ “[សិទ្ធិ] របស់ជនជាប់ចោទដែលមានចែងនៅក្នុងមាត្រា ១៤ និង ១៥ នៃអនុសញ្ញាអន្តរជាតិឆ្នាំ១៩៦៦ ស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ត្រូវតែបានគោរពនៅទូទាំងដំណើរការនៃការជំនុំជម្រះក្តី”។

ដែលទទួលស្គាល់ដោយសហគមន៍នៃប្រជាជាតិ[8]។

១០. មាត្រា ៦ នៃក្រមព្រហ្មទណ្ឌកម្ពុជាឆ្នាំ១៩៥៦ (“ក្រមព្រហ្មទណ្ឌឆ្នាំ១៩៥៦”) បានចែងអំពីគោលការណ៍មូលដ្ឋាននេះក្នុងន័យចង្អៀត៖

ច្បាប់ព្រហ្មទណ្ឌគ្មានអនុភាពប្រតិសកម្មទេ។ គ្មានអំពើឧក្រិដ្ឋណាមួយត្រូវបានផ្តន្ទាទោសដោយការដាក់ទោស ដែលពុំត្រូវបានប្រកាសដោយច្បាប់មុនពេលអំពើនោះត្រូវបានប្រព្រឹត្ត ។ ថ្វីបើដូច្នេះ នៅក្នុងពេលច្បាប់ធ្វើការលុបបំបាត់ការរំលោភ ឬកាត់បន្ថយទោស សេចក្តីសម្រេចគតិយុត្តិថ្មីនេះអាចដាក់ឱ្យអនុវត្តបានចំពោះការរំលោភច្បាប់ពីពេលអតីតកាល បើទោះជាការរំលោភដែលត្រូវគេរកឃើញនោះ ត្រូវបានប្រព្រឹត្តមុនពេលមានការអនុម័តច្បាប់ថ្មីនេះក្តី ក៏ត្រូវធ្វើក្រោមលក្ខខណ្ឌដែលថាគ្មានការផ្តន្ទាទោសជាក់លាក់ណាមួយបានកើតឡើងឡើយ[9]។

១១. ការហាមឃាត់ដ៏តឹងរ៉ឹងអំពីច្បាប់ព្រហ្មទណ្ឌដែលមានអានុភាពប្រតិសកម្ម ដែលរកឃើញនៅក្នុងក្រមព្រហ្មទណ្ឌឆ្នាំ ១៩៥៦[10] ត្រូវបានបង្កើតឡើងដោយកិច្ចព្រមព្រៀងសន្តិភាពទីក្រុងប៉ារីស ដែល

---

[8] មាត្រា១៥ នៃកតិកាសញ្ញា អន្តរជាតិ ស្តីពី សិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ បានអនុម័តនិងបើកឱ្យចុះហត្ថលេខា ឱ្យសច្ចាប័ន និងឱ្យចូលជាសមាជិកតាមសេចក្តីសម្រេចចិត្តលេខ២២០០ A (XXI) ចុះថ្ងៃទី១៦ ខែធ្នូ ឆ្នាំ១៩៦៦ របស់មហាសន្និបាតអង្គការសហប្រជាជាតិ ចូលជាធរមាននៅថ្ងៃទី២៣ ខែមីនា ឆ្នាំ១៩៧៦ ។ គោលការណ៍នេះត្រូវបានលើកឡើងស្រដៀងគ្នានៅក្នុងពហុភាពនៃលិខិតុបករណ៍សិទ្ធិមនុស្សផ្សេងៗទៀត។ *សូមមើល*សន្ធិសញ្ញាអឺរុបស្តីពីសិទ្ធិមនុស្ស និងសេរីភាពជាមូលដ្ឋាន មាត្រា៧។ អនុសញ្ញាអន្តរអាមេរិកកាំង ស្តីពីសិទ្ធិមនុស្ស មាត្រា៩។ ធម្មនុញ្ញអាហ្វ្រិកនៃសិទ្ធិមនុស្សនិងពលរដ្ឋ មាត្រា៧ (២)។ លក្ខន្តិកៈក្រុងរ៉ូមនៃតុលាការព្រហ្មទណ្ឌអន្តរជាតិ មាត្រា២២, ២៤។ សន្និបាទក្រុងហ្សឺណែវលើកទីបី ឆ្នាំ១៩៤៩ មាត្រា៩៩។ សន្និសីទក្រុងហ្សឺណែវលើកទីបួន ឆ្នាំ១៩៤៩ មាត្រា៦៧។ វាក៏ត្រូវបានទទួលស្គាល់ផងដែរដោយតុលាការ ICTY ។ *សូមមើល ជាឧទាហរណ៍, រឿងក្តីរដ្ឋអាជ្ញា តទល់ Vasiljević,* IT-98-32-T សាលក្រម ចុះថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ២០០២, កថាខណ្ឌ១៩៣។ *រឿងក្តីរដ្ឋអាជ្ញា តទល់ Galić*, IT-98-29-T សាលក្រម ចុះថ្ងៃទី៥ ខែធ្នូ ឆ្នាំ២០០៣, កថាខណ្ឌ៩២។

[9] ការបកប្រែភាសាក្រៅផ្លូវការពីអត្ថបទជាភាសាបារាំង។

[10] ក្រុមប្រឹក្សាធម្មនុញ្ញកម្ពុជាបានទទួលស្គាល់ថា គោលការណ៍នេះគឺជាគោលការណ៍សារវ័ន្តមានចែងនៅក្នុងក្រមព្រហ្មទណ្ឌ ១៩៥៦។ ប៉ុន្តែ នៅពេលដែលក្រុមប្រឹក្សាធម្មនុញ្ញបានពិចារណាថា តើវិសាលភាពនៃអាជ្ញាយុកាលសម្រាប់បទល្មើសដែលគ្របដណ្តប់ដោយក្រមព្រហ្មទណ្ឌ ១៩៥៦ នឹងរំលោភរដ្ឋធម្មនុញ្ញកម្ពុជាដែរឬអត់នោះ វាហាក់ដូចរកឃើញថាមិនមានការរំលោភទៅវិញ ក្រោយពេលដែលគោលការណ៍ *គ្មានបទល្មើស បើគ្មានច្បាប់ចែង* មិនត្រូវបានគេឃើញមានចែងនៅក្នុងរដ្ឋធម្មនុញ្ញកម្ពុជាឡើយ។ *សូមមើល* សេចក្តីសម្រេចរបស់ក្រុមប្រឹក្សាធម្មនុញ្ញ លេខ ០៤០/០០២/២០០១ ចុះថ្ងៃទី ១២ កុម្ភៈ ២០០១។ សេចក្តីសម្រេចនេះមានកំហុសឆ្គងត្រង់ មាត្រា ៣១ នៃរដ្ឋធម្មនុញ្ញមានចែងយ៉ាងច្បាស់លាស់ថា កម្ពុជាត្រូវគោរពសិទ្ធិមនុស្សដូចមានចែងក្នុងសេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស និងលិខិតូបករណ៍សិទ្ធិមនុស្សដទៃទៀត។ គោលការណ៍ *គ្មានបទល្មើស បើ*

បានឈានទៅដល់ការអនុម័តច្បាប់រដ្ឋធម្មនុញ្ញកម្ពុជាឆ្នាំ ១៩៩៣[11]។ ដូច្នេះវិសាលភាពនៃការការពារដែលមានចែងនៅក្នុងច្បាប់កម្ពុជា ប្រឆាំងនឹងភាពប្រតិសកម្មនៃច្បាប់ព្រហ្មទណ្ឌ ហើយពង្រីកវិសាលបន្ថែមទៀតក្នុងអនុញ្ញាតដោយកតិកាសញ្ញា ICCPR ដែលគ្រាន់តែចែងពីការធានាជាអប្បបរិមា។ ដូចមានចែងក្នុង មាត្រា ៥ (២) នៃកតិកាសញ្ញា ICCPR ក្នុងពេលដែលមានការការពារសិទ្ធិនេះមានលក្ខណៈទូលំទូលាយក្នុងថ្នាក់ជាតិជាងកម្រិតអន្តរជាតិ នោះបទបញ្ញត្តិជាតិមានអធិកភាព និងត្រូវដាក់ឲ្យអនុវត្ត[12]។ នេះជាការពិតក្នុងករណីបច្ចុប្បន្នដែលកតិកាសញ្ញាស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយដែលកម្ពុជាបានចុះហត្ថលេខា និងផ្តល់សច្ចាប័ន បន្ទាប់ពីការកើតមានឧក្រិដ្ឋកម្មដែលបានចោទប្រកាន់[13]។

១២. គោលបំណងនៃគោលការណ៍ *គ្មានបទល្មើសបើគ្មានច្បាប់ចែង* នេះគឺដើម្បី "ការពារពលរដ្ឋឲ្យបានរឹងមាំតាមលទ្ធភាពធ្វើទៅបាន ប្រឆាំងនឹងអំណាចតាមទំនឹងចិត្តរបស់រដ្ឋាភិបាល និងឆន្ទានុសិទ្ធិ

---

*គ្មានច្បាប់ចែង* គេឃើញមានចែងនៅក្នុងលិខិតូបករណ៍ទាំងនេះ។ ម្យ៉ាងវិញទៀត ក្រុមប្រឹក្សាធម្មនុញ្ញបានសម្រេចដោយមិនសមរម្យដោយមិនអើពើមាត្រា ៦ នៃក្រមព្រហ្មទណ្ឌ ១៩៥៦។ ក្រុមប្រឹក្សាធម្មនុញ្ញមិនត្រូវបានគេស្នើអោយត្រួតពិនិត្យធម្មនុញ្ញភាពនៃមាត្រា ៦ នៃក្រមព្រហ្មទណ្ឌ ១៩៥៦ នេះទេ ខណៈដែលខ្លួនមានអំណាចដើម្បីធ្វើតាមសំណើសុំអនុលោមតាមមាត្រា១៤១ថ្មី នៃរដ្ឋធម្មនុញ្ញកម្ពុជា ហើយមិនបានសម្រេចថា មាត្រានេះគឺមិនស្របនឹងរដ្ឋធម្មនុញ្ញ ខណៈដែលខ្លួនអាចធ្វើដូច្នេះបានអនុលោមតាមមាត្រា ១៤២ថ្មី នៃរដ្ឋធម្មនុញ្ញ។ ក្រុមប្រឹក្សាធម្មនុញ្ញបានត្រឹមតែសម្រេចមិនអើពើបទបញ្ញត្តិប្រឆាំងនឹងការអនុវត្តន៍ប្រតិសកម្មនៃច្បាប់ព្រហ្មទណ្ឌដែលគេឃើញមានចែងក្នុងមាត្រា ៦ ខណៈដែលបណ្តោយអោយក្រមនេះនៅជាធរមានដដែល។ ជាការច្បាស់ណាស់ថា សេចក្តីសម្រេចនេះត្រូវបានធ្វើឡើងគឺដើម្បីសម្រេចទៅតាមលទ្ធផលមួយដែលគេចង់បាន ដោយមិនខ្វាយខ្វល់អំពីមូលដ្ឋានសំអាងផ្លូវច្បាប់ជាក់ស្តែងរបស់ខ្លួន។ កម្ពុជាត្រូវតែគោរពច្បាប់ជាធរមានរបស់ខ្លួន និងមិនអាចមិនអើពើបទបញ្ញត្តិនានានៃច្បាប់របស់ខ្លួនដែលខ្លួនយល់ឃើញថាមិនមានប្រយោជន៍ ដោយមិនបានប្រើប្រាស់នីតិវិធីសមរម្យដើម្បីកែប្រែច្បាប់របស់ខ្លួន។

[11] *សូមមើល* គោលការណ៍សម្រាប់រដ្ឋធម្មនុញ្ញថ្មីសម្រាប់ប្រទេសកម្ពុជា ទៅនឹងកិច្ចព្រមព្រៀងស្តីពីដំណោះស្រាយនយោបាយដ៏ទូលំទូលាយនៃជម្លោះកម្ពុជា ចុះថ្ងៃទី២៣ ខែតុលា ឆ្នាំ១៩៩១ ឧបសម្ព័ន្ធ៥ គោលការណ៍ទី២។

[12] មាត្រា៥(២) នៃ ICCPR ចែងថា "មិន[ត្រូវ]ធ្វើការរិតត្បិត ឬបដិប្បញ្ញត្តិណាមួយឡើយទៅលើសិទ្ធិមូលដ្ឋានរបស់មនុស្សដែលត្រូវបានទទួលស្គាល់ ឬដែលនៅជាធរមានក្នុងរដ្ឋភាគីនៃកតិកាសញ្ញានេះ ដោយអនុលោមទៅតាមច្បាប់អនុសញ្ញា បទបញ្ជា ឬទំនៀមទម្លាប់ ដោយយកលេសថាកតិកាសញ្ញានេះមិនទទួលស្គាល់សិទ្ធិទាំងនោះក្នុងកម្រិតតិចជាង"។ បទប្បញ្ញត្តិនេះការពារជាសំខាន់នូវភាពសក្តិសិទ្ធនៃច្បាប់ណាដែលកំណត់ការការពារកម្រិតខ្ពស់សម្រាប់សិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ជាងប្បញ្ញត្តិដែលមានចែងក្នុង ICCPR។ *សូមមើល* MANFRED NOVAK, UN COVENANT ON CIVIL AND POLITICAL RIGHTS: ICCPR COMMENTARY 118 (N.P. Engel Publisher, 2005)។

[13] កម្ពុជាបានចុះហត្ថលេខាICCPRនៅថ្ងៃទី១៧ ខែតុលា ឆ្នាំ១៩៨0 និងបានអនុម័ត នៅថ្ងៃទី២៦ ខែឧសភា ឆ្នាំ១៩៩២, http://treaties.un.org/Pages/ViewDetails.aspx?src=TREATY&mtdsg_no=IV-4&chapter=4&lang=en ។

ហួសហេតុរបស់តុលាការ។ ជារួម មូលដ្ឋានគ្រឹះនៃទស្សនៈនេះវាស្ថិតនៅលើការសន្មត *ការលំអៀងមកខាងជនជាប់ចោទ* favor rei (ដែលមានទំនោរទៅរកជនជាប់ចោទ) (ផ្ទុយពី *ពីការលំអៀងមកខាងសង្គម* favor societatis ឬដែលមានទំនោរទៅរកសង្គម[14]") ។

## II. ទឡ្ហីករណ៍

### ក. ឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ពុំត្រូវបានចាត់ទុកជាបទល្មើសនៅក្នុងច្បាប់ជាតិរបស់កម្ពុជាទេ

#### i. ឧក្រិដ្ឋកម្មប្រល័យពូជសាសន៍គ្មានចែងនៅក្នុងក្រមព្រហ្មទណ្ឌឆ្នាំ១៩៥៦ទេ

១៣. ក្នុងនាមជាតុលាការកម្ពុជា អ.វ.ត.ក មានកាតព្វកិច្ចអនុវត្តតាមច្បាប់កម្ពុជា[15]។ ក្រមព្រហ្មទណ្ឌឆ្នាំ ១៩៥៦ ត្រូវបានទទួលស្គាល់ជាផ្លូវការថាជាក្រមកំពុងអនុវត្តនៅកម្ពុជាអំឡុងឆ្នាំ១៩៧៥-១៩៧៩ ក្នុងពេលនៃការប្រព្រឹត្តិឧក្រិដ្ឋកម្មដែលបានចោទប្រកាន់[16]។ ក្រមព្រហ្មទណ្ឌនេះពុំមានបទប្បញ្ញត្តិណាមួយចាត់ទុកអំពើប្រល័យពូជសាសន៍ថាជាបទល្មើសឡើយ។ ដូច្នេះគេពុំអាចយក ក្រមព្រហ្មទណ្ឌឆ្នាំ ១៩៥៦ នេះដើម្បីធ្វើជាមូលដ្ឋានដើម្បីចោទប្រកាន់អំពីបទប្រល័យពូជសាសន៍បានឡើយ។

១៤. ការចោទប្រកាន់ និងឈានទៅដល់ការផ្តន្ទាទោស ជនសង្ស័យ ឬ ជនជាប់ចោទ តាមក្រមនេះចំពោះអំពើទាំងឡាយដែលការពិតពុំបានរំលោភបំពានលើក្រមនេះគឺជាការរំលោភគោលការណ៍ *គ្មានបទល្មើសបើគ្មានច្បាប់ចែង* ដែលតម្រូវថា អំពើដែលអាចផ្តន្ទាទោសបានគឺជាអំពើទាំងឡាយណាដែលបង្កើតបានជាបទល្មើសនៅពេលដែលមានបទល្មើសនោះកើតឡើង[17]។ ការខកខានពុំបាន

---

[14] CASESSE នៅទំព័រ ១៥២។

[15] *សូមមើល* មាត្រា១២(១) នៃកិច្ចព្រមព្រៀង។ *សូមមើលផងដែរ* បុព្វកថា នៃវិធានផ្ទៃក្នុងវិសោធនកម្មលើកទី៤ ចុះថ្ងៃទី ១១ ខែកញ្ញា ឆ្នាំ២០០៩។

[16] *សូមមើល រឿងក្តី កាំង ហ្កេកអ៊ាវ ហៅ "ឌុច"* សំណុំរឿងលេខ ០០១/១៨-០៧-២០០៧-អ.វ.ត.ក/អ.ជ.ស.ដ ព័ត៌មានអំពីក្រមព្រហ្មទណ្ឌឆ្នាំ១៩៥៦ នៃប្រទេសកម្ពុជា និងសំណើយថាភាពនៃក្រមអាជ្ញា ចុះថ្ងៃទី១៧ ខែសីហា ឆ្នាំ២០០៩ ឯកសារ E91/5, ERN: 00365471-00365472 ។

[17] *សូមមើល* Helmut Kreicker, *ការចោទប្រកាន់ថ្នាក់ជាតិចំពោះឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ដែលចេញពីទស្សនាទានប្រៀបធៀប* (*National Prosecution of Genocide from a Comparative Perspective*), 5 INT'L CRIM. L. REV. 313, 320-321(2005), (ហៅកាត់ថា "Kreicker") ដែលគាត់ផ្តល់អំណះអំណាងថា មានតែច្បាប់ព្រហ្មទណ្ឌជាតិជាលាយលក្ខណ៍អក្សរ

គោរពគោលការណ៍ *គ្មានបទល្មើស បើគ្មានច្បាប់ចែង* គឺជាការរំលោភរដ្ឋធម្មនុញ្ញកម្ពុជា[18] ព្រមទាំងរំលោភមាត្រា ៦ នៃក្រមព្រហ្មទណ្ឌកម្ពុជាឆ្នាំ១៩៥៦[19]ទៀតផង។

**ii. កិច្ចព្រមព្រៀង និងច្បាប់ស្តីពីការបង្កើតឱ្យមាន អ.វ.ត.ក ពុំបង្កើតឱ្យមានច្បាប់ថ្មីឡើយ ពោលគឺគ្រាន់តែផ្តល់យុត្តាធិការឱ្យ អ.វ.ត.ក យកច្បាប់ដែលមានស្រាប់មកអនុវត្តប៉ុណ្ណោះ**

១៥. កិច្ចព្រមព្រៀង និងច្បាប់ស្តីពីការបង្កើតឱ្យមាន អ.វ.ត.ក ពុំបង្កើតឱ្យមានច្បាប់សារធាតុព្រហ្មទណ្ឌជាតិថ្មីឡើយ។ កិច្ចព្រមព្រៀងត្រូវបានបង្កើតឡើងដើម្បីកំណត់កិច្ចសហប្រតិបត្តិការរវាងអង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជាក្នុងការកាត់សេចក្តីមេដឹកនាំជាន់ខ្ពស់នៃរបបកម្ពុជាប្រជាធិបតេយ្យ និងអ្នកទទួលខុសត្រូវខ្ពស់បំផុតចំពោះឧក្រិដ្ឋកម្ម និងការរំលោភធ្ងន់ធ្ងរទៅលើច្បាប់ព្រហ្មទណ្ឌកម្ពុជា ច្បាប់មនុស្សធម៌អន្តរជាតិ និងទំនៀមទម្លាប់អន្តរជាតិ និងអនុសញ្ញាអន្តរជាតិដែលកម្ពុជាទទួលស្គាល់[20]។ ច្បាប់ស្តីពីការបង្កើតឱ្យមាន អ.វ.ត.ក ត្រូវបានបង្កើតឡើងដើម្បី "កាត់សេចក្តីមេដឹកនាំជាន់ខ្ពស់នៃរបបកម្ពុជាប្រជាធិបតេយ្យ និងអ្នកទទួលខុសត្រូវខ្ពស់បំផុតចំពោះ

---

និងកំណត់ជាក់លាក់ដែលគេងាយរកមើលបានតែប៉ុណ្ណោះ ទើបអាចអោយបុគ្គលម្នាក់ដឹងថាអំពើរបស់គាត់នឹងធ្វើឱ្យគាត់ទទួលខុសត្រូវព្រហ្មទណ្ឌ។

[18] យោងតាមមាត្រា៣១ នៃរដ្ឋធម្មនុញ្ញរបស់ព្រះរាជាណាចក្រកម្ពុជា ឆ្នាំ១៩៩៣ ដែលបានវិសោធនកម្មថ្ងៃទី៤ ខែមីនា ឆ្នាំ១៩៩៩ "[ព្រះ]រាជាណាចក្រកម្ពុជា<u>ទទួលស្គាល់ និងគោរព</u>សិទ្ធិមនុស្ស ដូចមានចែងក្នុងធម្មនុញ្ញនៃអង្គការសហប្រជាជាតិ សេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស និងកតិកាសញ្ញាព្រមទាំងអនុសញ្ញាទាំងឡាយទាក់ទងនឹងសិទ្ធិមនុស្សសិទ្ធិនារី និងសិទ្ធិកុមារ"។

[19] *សូមមើល* Bert Swart, *តុលាការដែលមានលក្ខណៈអន្តរជាតិ និងច្បាប់ព្រហ្មទណ្ឌសារធាតុ* នៅក្នុងបណ្តាតុលាការ និងអង្គជំនុំជម្រះដែលមានលក្ខណៈអន្តរជាតិដូចជានៅ ប្រទេសសៀរ៉ាលេអូន ប្រទេសទីម័រខាងកើត ប្រទេសកូសូវ៉ូ និងប្រទេសកម្ពុជា (*Internationalized Courts and Substantive Criminal Law*, *in* INTERNATIONALIZED CRIMINAL COURTS AND TRIBUNALS: SIERRA LEONE, EAST TIMOR, KOSOVO AND CAMBODIA) នៅទំព័រ 291, 310 (Cesare P.R. Romano, ed., 2004). "អាច[មាន] ករណីដែលជនជាប់ចោទអាចត្រូវទទួលខុសត្រូវអនុលោមតាមច្បាប់អន្តរជាតិ ប៉ុន្តែមិនអនុលោមទៅតាមច្បាប់ជាតិ។ ឧទាហរណ៍ទំនងបំផុតនៃស្ថានភាពដូចនេះ ប្រហែលជាឧទាហរណ៍មួយដែលនៅពេលប្រព្រឹត្តនោះ ច្បាប់ជាតិមិនទាន់បានចាត់ទុកថាជាបទល្មើសគ្រប់គ្រាន់ទាក់ទងនឹងឧក្រិដ្ឋកម្មក្រោមច្បាប់អន្តរជាតិជាទូទៅ។ <u>គោលការណ៍ថ្នាក់ជាតិទាក់ទងនឹង *គ្មានច្បាប់ គ្មានបទល្មើស* nullum crimen អាចធ្វើឱ្យតុលាការដែលមានលក្ខណៈអន្តរជាតិ មិនអាចចៀសរួចពីការលើកលែងចោទប្រកាន់ជនជាប់ចោទ</u> បើទោះបីជាមាត្រា១៥(២) នៃកតិកាសញ្ញាអន្តរជាតិ ដែលនឹងប្រហែលជាមិនរារាំងការអនុវត្តប្រតិសកម្មនូវការអនុវត្តថ្នាក់ជាតិចំពោះច្បាប់ជាតិដែលចាត់ជាទុកជាបទល្មើសព្រហ្មទណ្ឌចំពោះ "អំពើ ឬការខកខាននោះជាបទល្មើសព្រហ្មទណ្ឌ ស្របតាមគោលការណ៍ទូទៅនៃច្បាប់ ដែលទទួលស្គាល់ដោយសហគមន៍នៃប្រជាជាតិ" ។ (គូសបញ្ជាក់បន្ថែម) ។

[20] កិច្ចព្រមព្រៀង មាត្រា១ ។

ឧក្រិដ្ឋកម្ម និងការរំលោភធ្ងន់ធ្ងរទៅលើច្បាប់ព្រហ្មទណ្ឌកម្ពុជា ច្បាប់ និងទំនៀមទម្លាប់មនុស្សធម៌អន្តរជាតិ និងអនុសញ្ញាអន្តរជាតិដែលកម្ពុជាទទួលស្គាល់[21]" ។ ដូច្នេះតួនាទីរបស់កិច្ចព្រមព្រៀងគឺដើម្បីបង្កើតឡើងនូវកិច្ចសហប្រតិបត្តិការរវាងអង្គការសហប្រជាជាតិ និងរដ្ឋាភិបាល កម្ពុជា ខណៈពេលដែលតួនាទីរបស់ច្បាប់ស្ដីពីការបង្កើតឲ្យមាន អ.វ.ត.ក គឺដើម្បីដាក់ឲ្យអនុវត្តជាក់ស្ដែងនូវកិច្ចសហប្រតិបត្តិការនេះ ក្នុងនោះមានដូចជាតាមរយៈការកំណត់យុត្តាធិការរបស់ អ.វ.ត.ក លើរឿងក្ដីទៅលើពេលវេលា និងទៅលើបុគ្គល។

១៦. ដូច្នេះ មាត្រា ៤ នៃច្បាប់ស្ដីពីការបង្កើតឲ្យមាន អ.វ.ត.ក គ្រាន់តែចែងអំពីនិយមន័យនៃឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ដែល អ.វ.ត.ក នឹងមានយុត្តាធិការទៅលើ បើសិនជាវាអាចផ្ដន្ទាទោសបានក្រោមច្បាប់សារធាតុដែលនៅជាធរមាន។ មាត្រានេះមិនបង្កើតឲ្យមានឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ជាច្បាប់សាធារតុមួយដែលយកមកអនុវត្តជាប្រតិសកម្មបានឡើយ។ មាត្រានេះក៏ពុំបានអនុវត្តនូវអនុសញ្ញាប្រល័យពូជសាសន៍ក្នុងប្រព័ន្ធច្បាប់ជាតិរបស់កម្ពុជាដែរ។ វាពុំអាចទេ។ បើគេយកវាមកអនុវត្តនោះនឹងជា ការរំលោភគោលការណ៍ *គ្មានបទល្មើស បើគ្មានច្បាប់ចែង* ដូច្នេះហើយវារំលោភច្បាប់កម្ពុជា។

## ខ. ច្បាប់សារធាតុព្រហ្មទណ្ឌអន្តរជាតិ ពុំអាចត្រូវបានយកមកអនុវត្តផ្ទាល់ក្នុងតុលាការកម្ពុជាបានឡើយ

១៧. អ.វ.ត.ក គឺជាតុលាការជាតិបង្កើតឡើងក្នុងរចនាសម្ព័ន្ធតុលាការដែលមានស្រាប់របស់ប្រព័ន្ធច្បាប់ជាតិរបស់កម្ពុជា[22]។ ទោះបីច្បាប់សារធាតុព្រហ្មទណ្ឌអន្តរជាតិផ្អែកទៅលើមូលដ្ឋាននៃអនុសញ្ញាអន្តរជាតិ ឬច្បាប់ទំនៀមទម្លាប់អន្តរជាតិក្ដី ក៏ច្បាប់នេះពុំអាចនឹងត្រូវបានគេយកមកអនុវត្តផ្ទាល់នៅក្នុងតុលាការកម្ពុជាបានឡើយ។ នេះមកពីកម្ពុជាប្រកាន់យកប្រព័ន្ធទ្វិកនិយម (dualist) ដែលផ្ទុយពី

---

[21] ច្បាប់ស្ដីពីការបង្កើត អវតក មាត្រា ១ ។

[22] បញ្ហានេះត្រូវបានបញ្ជាក់ដោយ អង្គបុរេជំនុំជម្រះ ក្នុងសេចក្ដីសម្រេចដំបូងរបស់ខ្លួន។ អង្គជំនុំជម្រះបានលើកឡើងថា " "ក្នុងការអនុវត្តជាក់ស្ដែង និងតាមផ្លូវច្បាប់ អ.វ.ត.ក គឺជាស្ថាប័នឯករាជ្យ ហើយដំណើរប្រតិបត្តិការរបស់ខ្លួន ក៏ឯករាជ្យផងដែរនៅក្នុងរចនាសម្ព័ន្ធតុលាការជាតិ"។ *រឿងក្ដី កាំង ហ្គេកអ៊ាវ ហៅ "ឌុច" សំណុំរឿងលេខ* 00១/១៨-0៧-២00៧-អ.វ.ត.ក-ក.ស.ច.ស (អ.ប.ជ0១) សាលដីកាលើបណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាឃុំខ្លួនបណ្ដោះអាសន្នរបស់ជនត្រូវចោទ កាំង ហ្គេកអ៊ាវ ហៅ "ឌុច" ចុះថ្ងៃទី៣ ខែធ្នូ ឆ្នាំ២00៧ កថាខណ្ឌ១៩ ។ (គូសបញ្ជាក់បន្ថែម)។

ប្រព័ន្ធឯកនិយម (monist)[23] នៅក្នុងវិធីសាស្ត្ររបស់ខ្លួនដើម្បីអនុវត្តច្បាប់អន្តរជាតិប្រព័ន្ធច្បាប់ជាតិ[24]។

១៨. ការប្រកាន់យកប្រព័ន្ធឯកនិយម ឬទ្វិកនិយមគឺដើម្បីកំណត់យន្តការដែលរដ្ឋប្រើប្រាស់ដើម្បីផ្តល់ប្រសិទ្ធភាពដល់កាតព្វកិច្ចអន្តរជាតិរបស់ខ្លួន។ រដ្ឋដែលប្រកាន់យកប្រព័ន្ធទ្វិកនិយមចាត់ទុកច្បាប់អន្តរជាតិថាមានលក្ខណៈដោយឡែកពីច្បាប់ជាតិ[25]។ ច្បាប់អន្តរជាតិត្រូវបានគេយកមកអនុវត្តនៅ

---

[23] "អ្នកប្រកាន់ប្រព័ន្ធឯកនិយម អះអាងថាប្រព័ន្ធច្បាប់មានតែមួយ ដោយច្បាប់អន្តរជាតិគឺជាធាតុផ្សំមួយ "ជាមួយផ្នែកផ្សេងៗនៃច្បាប់ជាតិ"។ សម្រាប់ Monist ច្បាប់អន្តរជាតិគឺគ្រាន់តែជាផ្នែកមួយនៃច្បាប់ជាតិ ជាមួយនឹងវង្វង់នៃច្បាប់ជាតិដែលគេស្គាល់។ អ្នកប្រកាន់ប្រព័ន្ធទ្វិកនិយមអះអាងថាប្រព័ន្ធច្បាប់មានចំនួន២ខុសគ្នា ហើយមានអត្ថិភាព "ជាផ្នែកក្នុងវង្វង់នៃសកម្មភាពខុសគ្នាដែលនោះគឺកម្រិតជាតិ និងកម្រិតអន្តរជាតិ"។ Michael Kirby, The Growing Rapprochement between International Law and National Law, in LEGAL VERSIONS OF THE 21ST CENTURY: ESSAYS IN HONOUS OF JUDGE CHRISTOPHER (Antony Anghie & Garry Sturgess eds. 1998) ដោយដកស្រង់សម្តី ROSALYN HIGGINS, PROBLEMS AND PROCESS – INTERNATIONAL LAW AND HOW WE USE IT 205 (Oxford, 1994)។ ថ្វីបើ ប្រទេសបារាំង ដែលប្រព័ន្ធច្បាប់របស់ខ្លួនត្រូវបានកម្ពុជាយកធ្វើជាគំរូតាម គឺជាប្រព័ន្ធឯកនិយមយ៉ាងហោចណាស់ទាក់ទងនឹងអនុសញ្ញាអន្តរជាតិ វាមានលក្ខណៈច្បាស់លាស់ណាស់តាមរយៈការប្រៀបធៀបរវាងរដ្ឋធម្មនុញ្ញកម្ពុជា និងបារាំង ដែលកម្ពុជាមិនយកលំនាំតាមវិធីសាស្ត្រស្រដៀងគ្នានេះទេ។ *សូមមើល* ជំពូក VI នៃរដ្ឋធម្មនុញ្ញបារាំង *ដែលអាចស្វែងរកបាននៅគេហទំព័រ* http://www.assemblee-nationale.fr/english/8ab.asp ដែលត្រូវបានគេប្រៀបធៀបជាមួយនឹងរដ្ឋធម្មនុញ្ញកម្ពុជា។ ភាពទីទៃពីគ្នារវាងប្រព័ន្ធរបស់កម្ពុជា និងបារាំង នៅក្នុងរឿងនេះគឺមិនទាក់ទងនឹងបញ្ហាណាមួយជាពិសេសឡើយ ដោយហេតុថាប្រទេសបារាំង នឹងមិនអនុវត្តដោយផ្ទាល់នូវអនុសញ្ញាមួយដែលមិនមានប្រសិទ្ធិភាពស្វ័យអនុវត្តឡើយ។ *សូមមើល See* ANTHONY AUST, MODERN TREATY LAW AND PRACTICE 146-47 (Cambridge University Press, 2000); TREATY MAKING – EXPRESSION OF CONSENT BY STATES TO BE BOUND BY A TREATY 89, 93-94 (Kluwer Law International 2001) (ហៅកាត់ថា "AUST")។

[24] មើលឯកសារអង្គការសហប្រជាជាតិ CERD/C/292/Add.2, ថ្ងៃទី៥ ខែឧសភា ឆ្នាំ១៩៩៧ កថាខណ្ឌ១៩ ដែលគណៈកម្មាធិការស្តីពីការលុបបំបាត់ការរើសអើងពូជសាសន៍បានយោងទៅដល់អនុសញ្ញាចំនួន ៨ ដែលកម្ពុជាបានផ្តល់សច្ចាប័ន ហើយបានថ្លែងថា វាពុំត្រូវបានសំអាងដោយផ្ទាល់នៅចំពោះមុខតុលាការកម្ពុជា ឬអាជ្ញាធររដ្ឋបាលឡើយ។ *សូមមើលផងដែរ* Suzannah Linton, *Putting Cambodia's Extraordinary Chambers into Context*, 11 S.Y.B.I.L.195, 203-204 (2007) ដែលគាត់បញ្ជាក់ថារដ្ឋាភិបាលកម្ពុជាមានការពេញចិត្តចំពោះប្រព័ន្ធ ទ្វិកនិយម។

[25] ក្នុងប្រព័ន្ធទ្វិកនិយម "ពេលអង្គនីតិបញ្ញត្តិ និងនីតិប្រតិបត្តិ ខកខានពុំបានចាត់វិធានការអនុវត្តឲ្យបានគ្រប់គ្រាន់ តុលាការជាតិជារឿយៗតែងតែជៀសវាងការតម្កល់ច្បាប់អន្តរជាតិតាមរយៈការយកមកអនុវត្តផ្ទាល់ ដោយយល់ឃើញថាពួកគេ ពុំអាចជំនួសឲ្យស្ថាប័ននយោបាយក្នុងការជ្រើសរើសទម្រង់នៃការអនុលោមតាមកាតព្វកិច្ចអន្តរជាតិ។ ក្នុងករណីនេះ សេរីភាពក្នុងការជ្រើសរើស *វិធី* អនុវត្តជាក់ស្តែងឈានសន្ធឹងទៅដល់សេរីភាពក្នុងការជ្រើសរើស *ថាតើ* ត្រូវអនុវត្តឬអត់"។ WARD N. FERDANANDUSSE, DIRECT APPLICATION OF INTERNATIONAL CRIMINAL LAW IN NATIONAL COURTS 142 (T.M.C. Asser Press 2006) [ចាប់ពីត្រឹមនេះតទៅហៅថា FERDINANDUSSE]។ សូមមើលផងដែរ ដូចឯកសារយោងខាងលើ ត្រង់១៣២ "ជាវិធានទូទៅ ច្បាប់អន្តរជាតិទុកឲ្យរដ្ឋមានសេរីភាពក្នុងការអនុវត្ត និងបំពេញកាតព្វកិច្ច

ក្នុងប្រព័ន្ធនេះប្រសិនបើ៖ (១) ការអនុវត្តផ្ទាល់ត្រូវបានអនុញ្ញាតយ៉ាងច្បាស់លាស់ដោយរដ្ឋធម្មនុញ្ញ ឬ (២) ច្បាប់ជាតិដាក់ប្រកាសអោយប្រើបានយកច្បាប់អន្តរជាតិនោះច្របាច់បញ្ចូលទៅក្នុងប្រព័ន្ធច្បាប់ជាតិរបស់រដ្ឋនោះ[26]។ ចំពោះករណីអនុសញ្ញា ប្រសិនបើគ្មាន ច្បាប់ជាតិដាក់ប្រកាសអោយប្រើទេ អនុសញ្ញានោះត្រូវតែមានប្រសិទ្ធិភាពស្វ័យអនុវត្ត (self-executing) ទើបអាចយកមកអនុវត្តបានដោយផ្ទាល់[27]។

១៩. ក្នុងរឿងក្តី Nulyarimma ទល់នឹង Thompson គេអាចប្រទះឃើញឧទាហរណ៍មួយអំពីអ្វីដែលបានកើតឡើងក្នុងពេលរដ្ឋដែលប្រកាន់យកប្រព័ន្ធទ្វិកនិយម[28] ត្រូវបានគេស្នើឲ្យយកច្បាប់អន្តរជាតិមកអនុវត្តដោយពុំចាំបាច់មានការអនុញ្ញាតពីច្បាប់ ឬរដ្ឋធម្មនុញ្ញ[29]ឡើយ។ ក្នុងរឿងក្តីនេះ តុលាការសហព័ន្ធអូស្ត្រាលីបានបើកសវនាការលើរឿងក្តី២រួមគ្នា ដែលភាគីបណ្តឹងឧទ្ធរណ៍ជនជាតិអូស្ត្រាលីអ្នកស្រុកដើមបានលើកអំណះអំណាងថានាយករដ្ឋមន្ត្រី និងសមាជិករដ្ឋាភិបាលផ្សេងទៀតមានទោសពីបទប្រល័យពូជសាសន៍ចំពោះទង្វើដែលរួមចំណែកដល់ការបំផ្លាញប្រជាជនអ្នកស្រុកដើម ក្នុងនាមជាក្រុមជាតិពន្ធុ ឬជាតិសាសន៍មួយ។ ប្រទេសអូស្ត្រាលីបានផ្តល់សច្ចាប័នទៅលើ

---

អន្តរជាតិតាមមធ្យោបាយស័ក្តិសម។ ឧទាហរណ៍មួយនៃរឿងនេះអាចត្រូវបានគេមើលឃើញនៅក្នុងតុលាការប្រទេសអង់គ្លេស ដែលតុលាការនេះបានយល់ឃើញថា "កាតព្វកិច្ច ... ដែលត្រូវបានគេសន្មតតាមរយៈការផ្តល់សច្ចាប័ននូវ UNCAT គឺមិនអាចអនុវត្តបានដោយផ្ទាល់នៅក្នុងតុលាការអង់គ្លេសឡើយ ដោយហេតុថា "សន្ធិសញ្ញាអន្តរជាតិមិនអាចបង្កើតបានជាផ្នែកមួយនៃច្បាប់អង់គ្លេស ហើយតុលាការអង់គ្លេសមិនមានយុត្តាធិការដើម្បីបកស្រាយ ឬអនុវត្តសន្ធិសញ្ញាទាំងនេះឡើយ"" អត្ថបទរបស់ Rosemary Pattenden, *Admissibility in Criminal Proceedings of Third Party and Real Evidence Obtained by Methods Prohibited by UNCAT,* 10 INT'L J. EVIDENCE & PROOF 1, 29 (2006)។

[26] អត្ថបទរបស់ Gabriele Olivi, ក្រោមចំណងជើងថា *តួនាទីរបស់តុលាការជាតិនៅក្នុងការចោទប្រកាន់ឧក្រិដ្ឋកម្មអន្តរជាតិ៖ ទស្សនាទានថ្មី* (*The Role of National Courts in Prosecuting International Crimes: New Perspectives*) 18 SRI LANKA J. INT'L L. 83, 86-87 (2006). [ហៅកាត់ថា "Olivi"]

[27] លិខិតុបករណ៍ច្បាប់មួយ គឺមានប្រសិទ្ធិស្វ័យអនុវត្ត "ចូលជាធរមានភ្លាមដោយមិនចាំបាច់មានប្រភេទនៃអំពើអនុវត្តណាមួយនោះទេ"។ វចនានុក្រម BLACK'S LAW DICTIONARY 1364 (បោះពុម្ពដោយ West Publishing Co, ប្រែសម្រួលលើកទី៧ ឆ្នាំ១៩៩៩)។ *សូមមើលផងដែរ* William A. Schabas, *National Courts Finally Begin to Prosecute Genocide, the 'Crime of Crimes,'* 1 J. INT'L CRIM. JUST. 39, 62 (2003) [បន្ទាប់ពីនេះ *National Courts Finally Begin to Prosecute Genocide*]; MALCOLM N. SHAW QC, INTERNATIONAL LAW 263 (ប្រែសម្រួលលើកទី៥ ឆ្នាំ២០០៣) ដែលទាំងពីរនេះកត់សម្គាល់ថា អនុសញ្ញាអំពើប្រល័យពូជសាសន៍ មានប្រសិទ្ធភាពដោយស្វ័យប្រវត្តិ។

[28] ប្រទេសអូស្ត្រាលីអនុវត្តប្រព័ន្ធទ្វិកនិយម។ *សូមមើល* DAVID SLOSS, TREATY ENFORCEMENT IN DOMESTIC COURTS: A COMPARATIVE ANALYSIS ១៣ (Cambridge University Press 2009)។

[29] *រឿងក្តី Nulyarimma តទល់ Thompson* [1999] FCA 1192 (តុលាការសហព័ន្ធអូស្ត្រាលី)។

អនុសញ្ញាប្រល័យពូជសាសន៍ ប៉ុន្តែមិនបានអនុម័តច្បាប់ដាក់ប្រកាសអោយប្រើឡើយ។ តុលាការបានសម្រេចថា ឧក្រិដ្ឋកម្មប្រល័យពូជសាសន៍គ្មានអត្ថិភាពនៅក្នុងច្បាប់អូស្ត្រាលីទេ។ ដូច្នេះមន្ត្រីរដ្ឋាភិបាលពុំត្រូវបានកាត់សេចក្តីចំពោះអំពើប្រល័យពូជសាសន៍ឡើយ។ ចៅក្រម Justice Wilcox បានបញ្ជាក់ថា៖

> គេនិយាយបានម្យ៉ាងថា ប្រទេសអូស្ត្រាលីមានកាតព្វកិច្ចគតិយុត្តិអន្តរជាតិក្នុងការចោទប្រកាន់ ឬធ្វើបត្យាប័នជនសង្ស័យប្រព្រឹត្តអំពើប្រល័យពូជសាសន៍ដែលគេបានប្រទះឃើញក្នុងទឹកដីរបស់ខ្លួន ហើយសភាកុមម៉ុនវែល (Commonwealth Parliament) អាចបង្កើតច្បាប់ដើម្បីធានាឱ្យមានការបំពេញកាតព្វកិច្ចនោះ។ គេនិយាយបានម្យ៉ាងវិញទៀតថា បើគ្មានច្បាប់ចែងដូចខាងលើទេ ជននោះអាចត្រូវបានកាត់សេចក្តីពីបទប្រល័យពូជសាសន៍នៅចំពោះមុខតុលាការអូស្ត្រាលី។ ប្រសិនបើមានជំហរបែបនោះមែន វានឹងនាំទៅដល់លទ្ធផលដែលគួរឱ្យចង់ដឹងដែលថា កាតព្វកិច្ចអន្តរជាតិដែលកើតមានឡើងអនុលោមតាមច្បាប់ទំនៀមទម្លាប់នោះ វាមានផលវិបាកខាងផ្នែកជាតិធំធេងជាងកាតព្វកិច្ចដែលកើតមានឡើងតាមការស្ម័គ្រចិត្តច្បាស់លាស់ តាមរយៈការចុះហត្ថលេខា និងការផ្តល់សច្ចាប័នរបស់ប្រទេសអូស្ត្រាលីដល់អនុសញ្ញាអន្តរជាតិ។ ការផ្តល់សច្ចាប័នទៅឱ្យអនុសញ្ញាមួយវាពុំប៉ះពាល់ផ្ទាល់ដល់ច្បាប់អូស្ត្រាលីឡើយ លើកលែងតែ និងរហូតដល់ពេលមានការអនុម័តច្បាប់ដាក់ប្រកាសអោយប្រើ។ នេះហាក់ដូចជាជំហរមួយ ទោះបីនៅក្នុងពេលរដ្ឋសភាបានអនុម័តលើការផ្តល់សច្ចាប័ននោះរួចហើយក្តី ដូចក្នុងករណីអនុសញ្ញាប្រល័យពូជសាសន៍នេះឯង[30]។

ភាគីបណ្តឹងឧទ្ធរណ៍បានលើកទឡ្ហីករណ៍ថាអំពើប្រល័យពូជសាសន៍ គឺជាឧក្រិដ្ឋកម្មមួយប្រភេទដែលអាចផ្តន្ទាទោសបានតាមច្បាប់អន្តរជាតិ ថ្វីបើពុំមានច្បាប់ជាតិរបស់រដ្ឋប្រកាសថាឧក្រិដ្ឋកម្មនេះអាចផ្តន្ទាទោសបានក្តី។ ទោះបីជាយ៉ាងដូច្នេះក្តី Justice Wilcox បានបញ្ជាក់ថា "វាពុំទាន់គ្រប់គ្រាន់ក្នុងការនិយាយថា *តាមច្បាប់អន្តរជាតិ* ឧក្រិដ្ឋកម្មអន្តរជាតិមួយអាចផ្តន្ទាទោសបានក្នុងតុលាការជាតិ ទោះបីក្នុងច្បាប់ជាតិពុំមានចែងថាទង្វើនោះអាចផ្តន្ទាទោសបានក្តី។ ប្រសិនបើអំពើប្រល័យពូជសាសន៍ត្រូវបានគេចាត់ទុកថាអាចផ្តន្ទាទោសបាននៅប្រទេសអូស្ត្រាលីដោយសំអាងថា វាជាឧក្រិដ្ឋកម្មអន្តរជាតិ គេត្រូវបង្ហាញឱ្យឃើញថា *ច្បាប់អូស្ត្រាលី* ពិតជាបានអនុញ្ញាតឱ្យផ្តន្ទា

---

[30] *ដូចជើងទំព័រខាងលើ* កថាខណ្ឌ២០ (យោបល់របស់ Wilcox J.) ។

ទោសមែន[31]"។

២០. ការអនុម័តច្បាប់ស្តីពីការបង្កើតឱ្យមាន អ.វ.ត.ក របស់កម្ពុជា ពុំមែនមានន័យថាជាការយកច្បាប់ជាតិដាក់ប្រកាសអោយប្រើដែលចាំបាច់សម្រាប់អនុសញ្ញា ឬច្បាប់ទំនៀមទម្លាប់អន្តរជាតិ មកអនុវត្តដោយផ្ទាល់ក្នុងតុលាការកម្ពុជា ចំពោះអំពើដែលបានកើតឡើងមុនពេលមានការអនុម័តច្បាប់នេះឡើយ។ មាត្រា ១ និងមាត្រា ២ នៃច្បាប់ស្តីពីការបង្កើតឱ្យមាន អ.វ.ត.ក ចែងថាអង្គជំនុំជម្រះវិសាមញ្ញត្រូវបានបង្កើតឡើងដើម្បី "ជំនុំជម្រះ...ជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុតចំពោះឧក្រិដ្ឋកម្ម និងការរំលោភយ៉ាងធ្ងន់ធ្ងរទៅលើ... ច្បាប់មនុស្សធម៌អន្តរជាតិ និងទម្លាប់អន្តរជាតិ និងការរំលោភទៅលើអនុសញ្ញាអន្តរជាតិដែលប្រទេសកម្ពុជាទទួលស្គាល់..."។ ថ្វីបើក្នុងមាត្រាទាំងនេះ មានការបរិយាយទៅដល់អនុសញ្ញាអន្តរជាតិ និងមានពាក្យថា "ទម្លាប់" ក្តី ក៏គេពុំអាចអនុវត្តជាប្រតិសកម្មនូវអនុសញ្ញាប្រល័យពូជសាសន៍ ឬច្បាប់ទំនៀមទម្លាប់អន្តរជាតិក្នុងប្រព័ន្ធច្បាប់ជាតិនៅកម្ពុជាបានឡើយ។ ច្បាប់ស្តីពីការបង្កើតឱ្យមាន អ.វ.ត.ក ត្រូវបានអនុម័តក្នុងឆ្នាំ២០០១ ដូច្នេះច្បាប់នេះអាចត្រឹមតែរាប់បញ្ចូលនូវអនុសញ្ញា និងច្បាប់ទំនៀមទម្លាប់អន្តរជាតិទាក់ទិននឹងឧក្រិដ្ឋកម្មប្រព្រឹត្តក្រោយឆ្នាំ២០០១ប៉ុណ្ណោះ។ ការអនុញ្ញាតឱ្យច្បាប់ស្តីពីការបង្កើតឱ្យមាន អ.វ.ត.ក អនុវត្តជាប្រតិសកម្មនូវអនុសញ្ញា ឬរាប់បញ្ចូលនូវច្បាប់ទំនៀមទម្លាប់អន្តរជាតិដែលមានក្នុងចន្លោះឆ្នាំ១៩៧៥-១៩៧៩ គឺជាការរំលោភគោលការណ៍ *គ្មានបទល្មើស បើគ្មានច្បាប់ចែង*[32] និងច្បាប់កម្ពុជា។

## i. អនុសញ្ញាប្រឆាំងនឹងអំពើប្រល័យពូជសាសន៍មិនអាចយក មកអនុវត្តនៅក្នុងតុលាការកម្ពុជាដោយផ្ទាល់បានទេ

២១. អនុសញ្ញាប្រឆាំងនឹងអំពើប្រល័យពូជសាសន៍ មិនអាចយកមកអនុវត្តនៅក្នុងតុលាការកម្ពុជាដោយ

---

[31] *ដូចជើងទំព័រខាងលើ*, កថាខណ្ឌ២១-២២ (គូសបញ្ជាក់បន្ថែម)។

[32] *សូមមើល ជាឧទាហរណ៍* Senegal, Cour de Cassation, Souleymane Guengueng et autres Contre Hissène Habré, Arrêt no. 14, ចុះថ្ងៃទី២០ ខែមីនា ឆ្នាំ២០០១។ East Timor, តុលាការឧទ្ធរណ៍, Armando dos Santos, សេចក្តីសម្រេចបុគ្គសម្ព័ន្ធដែលអាចអនុវត្តន៍ ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០០៣ ទំព័រ១៤ ដែលតុលាការបានលើកឡើងថា "ទោះបីជាអំពើដែលបានប្រព្រឹត្តដោយចុងចោទក្នុងឆ្នាំ១៩៩៩ មានឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ដែលមានចែងក្រោមផ្នែក ៥.១(ក) នៃ UNTAET Regulation 200/15, ចុងចោទមិនអាចត្រូវបានកាត់ទោសក្រោម និង ផ្តន្ទាទោសផ្អែកទៅលើច្បាប់ព្រហ្មទណ្ឌនេះទេ ដែលមិនមាននៅលើកាលបរិច្ឆេទដែលអំពើទាំងនេះត្រូវបានប្រព្រឹត្ត និង ដូចអ្វីដែលបានបញ្ជាក់ មិនអាចត្រូវបានអនុវត្តជាប្រតិសកម្មទេ"។

ផ្ទាល់បានទេ[33]។ អនុសញ្ញាប្រឆាំងនឹងអំពើប្រល័យពូជសាសន៍នេះ មិនមានអានុភាពស្វ័យអនុវត្ត បានទេ[34] ហើយប្រទេសកម្ពុជា ក៏មិនបានអនុម័តច្បាប់ដាក់ប្រកាសអោយប្រើណាមួយដែលអាច ឱ្យយកអនុសញ្ញានេះមកអនុវត្តនៅក្នុងចន្លោះឆ្នាំពី ១៩៧៥-១៩៧៩ បានដែរ។ ប្រសិនបើប្រទេស កម្ពុជាអនុវត្តតាមប្រព័ន្ធឯកនិយមវិញ (monist system) ដែលពេលនោះរដ្ឋទទួលយក ច្បាប់អន្តរជាតិឱ្យក្លាយទៅជាប្រព័ន្ធច្បាប់ជាតិក៏ដោយ៖

> ក៏ការផ្តល់សច្ចាប័ន ឬទទួលយកចំពោះសន្ធិសញ្ញាអន្តរជាតិ នាំឱ្យទទួលស្គាល់បទដ្ឋាន នៃសន្ធិសញ្ញានេះទៅក្នុងច្បាប់ជាតិ និងធ្វើឱ្យបទដ្ឋានទាំងនោះអាចយកមកអនុវត្តដោយ ផ្ទាល់នៅចំពោះមុខតុលាការជាតិបាន ....។ យ៉ាងណាក៏ដោយ សន្ធិសញ្ញាមួយអាចត្រូវ យកមកអនុវត្តនៅក្នុងច្បាប់ជាតិ ដោយសំអាងទៅលើមូលដ្ឋាននេះបាន តែក្នុងករណីដែល សន្ធិសញ្ញានោះជាសន្ធិសញ្ញាមាន "អានុភាពស្វ័យអនុវត្ត" ច្រើនប៉ុណ្ណាតែប៉ុណ្ណោះ។ ... បទប្បញ្ញត្តិនៃអនុសញ្ញាប្រឆាំងនឹងអំពើប្រល័យពូជសាសន៍ មិនអាចយកមកអនុវត្តនៅក្នុង ច្បាប់ជាតិបានដោយងាយៗ ដោយមិនមានច្បាប់បន្ថែមខ្លះទៀតបាននោះទេ។ អាស្រ័យ ហេតុនេះ នៅក្នុងស្មារតីទូទៅ សន្ធិសញ្ញានេះមិនអាចអនុវត្តដោយឯងៗបាននោះទេ[35]។

២២. មាត្រាទី ៥ នៃអនុសញ្ញាប្រឆាំងនឹងអំពើប្រល័យពូជសាសន៍ តម្រូវឱ្យបណ្តារដ្ឋទាំងឡាយប្រតិបត្តិ តាមច្បាប់ជាតិ ដើម្បីផ្តល់អនុភាពដល់បញ្ញត្តិនានានៃអនុសញ្ញានេះ[36]។ ប៉ុន្តែ ប្រទេសកម្ពុជា មិន អនុម័តច្បាប់ជាតិដើម្បីដាក់បញ្ចូលអនុសញ្ញាប្រឆាំងនឹងអំពើប្រល័យពូជសាសន៍នេះទេ[37]។ ហើយ

---

[33] "ជាទូទៅ សន្ធិសញ្ញាសិទ្ធិមនុស្ស ក៏ដូចជាច្បាប់អន្តរជាតិជាទូទៅដែរ ត្រូវបានទទួលស្គាល់ថា មិនអាចយកមក អនុវត្ត ដោយ ផ្ទាល់ *ដោយខ្លួនឯងបានទេ*" ។ FERDINANDUSSE, AT 132 ។

[34] *តុលាការជាតិជាចុងក្រោយចាប់ផ្តើមកាត់ទោសអំពើប្រល័យពូជសាសន៍* ទំព័រ៦២។ *សូមមើលផងដែរ* MALCOLM N. SHAW QC, INTERNATIONAL LAW 263 (បោះពុម្ពលើកទី៥ ឆ្នាំ២00៣)។

[35] WILLIAM A. SCHABAS, អំពើប្រល័យពូជសាសន៍នៅក្នុងច្បាប់អន្តរជាតិ (GENOCIDE IN INTERNATIONAL LAW 341) (Cambridge University Press 2003) [បន្ទាប់ពីនេះទៅ អំពើប្រល័យពូជសាសន៍នៅក្នុងច្បាប់អន្តរជាតិ (GENOCIDE IN INTERNATIONAL LAW)] ។

[36] មាត្រា៥ ចែងថា៖ "ភាគីចុះកិច្ចសន្យាទទួលអនុម័ត ស្របជាមួយនឹងរដ្ឋធម្មនុញ្ញរបស់ខ្លួននូវច្បាប់ចាំបាច់ដើម្បីផ្តល់សុពលភាព ដល់ដល់បទប្បញ្ញត្តិនៃអនុសញ្ញាបច្ចុប្បន្ន និង ជាពិសេស ដើម្បីកំណត់ការផ្តន្ទាទោសដ៏មានប្រសិទ្ធភាពចំពោះជនណាដែលមាន ពិរុទ្ធភាពក្នុងអំពើប្រល័យពូជសាសន៍ ឬក្នុងអំពើណាផ្សេងទៀត ដូចដែលបានរៀបរាប់ក្នុងមាត្រា III"។

[37] *សូមមើល* អំពើប្រល័យពូជសាសន៍នៅក្នុងច្បាប់អន្តរជាតិ លេខយោងចុងទំព័រ ៣៤ )GENOCIDE IN INTERNATIONAL LAW, fn. 34), ដែលប្រទេសកម្ពុជាត្រូវបានដាក់ចូលទៅក្នុងបញ្ជីជារដ្ឋមួយ ក្នុងចំណោមរដ្ឋទាំងឡាយ

បទប្បញ្ញត្តិទាំងឡាយនៃរដ្ឋធម្មនុញ្ញកម្ពុជា ដែលនៅជាធរមាននាពេលដែលសកម្មភាពនៃអំពើប្រល័យពូជសាសន៍ ត្រូវបានចោទប្រកាន់ថាបានប្រព្រឹត្តឡើង មិនបានសំអាងទៅលើការដាក់បញ្ចូលអនុសញ្ញាប្រឆាំងនឹងអំពើប្រល័យពូជសាសន៍នោះដែរ[38]។ មានប្រទេសមួយចំនួនធំមិនទាន់បានដាក់បញ្ចូលពាក្យពេចន៍ នៃអនុសញ្ញាប្រឆាំងនឹងអំពើប្រល័យពូជសាសន៍ ទៅក្នុងក្រមព្រហ្មទណ្ឌរបស់ខ្លួននៅឡើយទេ។ ហើយការកត់ត្រានាពេលថ្មីៗនេះ នៃការផ្តន្ទាទោសដោយតុលាការជាតិ បង្ហាញឱ្យឃើញថា កង្វះខាតនៅក្នុងច្បាប់ព្រហ្មទណ្ឌក្នុងបណ្តារដ្ឋទាំងនេះ បាននាំឱ្យអំពើប្រល័យពូជសាសន៍មិនត្រូវបានទទួលស្គាល់នៅក្នុងច្បាប់ជាតិនោះឡើយ[39]។

២៣. ទោះបីប្រទេសកម្ពុជា បានយល់ព្រមទទួលយកអនុសញ្ញាប្រឆាំងនឹងអំពើប្រល័យពូជសាសន៍ កាល

---

ដែលមិនមានច្បាប់ជាតិដាក់ប្រកាសអោយប្រើសម្រាប់អនុសញ្ញាប្រឆាំងនឹងអំពើប្រល័យពូជសាសន៍។ ក្នុងពេលឆាប់ៗខាងមុខនេះ កម្ពុជានឹងអនុម័តក្រមព្រហ្មទណ្ឌថ្មី។ *សូមមើល* អត្ថបទរបស់ Chun Sakada *រដ្ឋសភាជាតិអនុម័តក្រមព្រហ្មទណ្ឌ* អត្ថបទព័ត៌មាន VoA ចុះថ្ងៃទី ១២ តុលា ២០០៩ ដែលអាចរកបាននៅគេហទំព័រ http://www.voanews.com/khmer/2009-10-12-voa9.cfm?renderforprint=1. ។ មាត្រា ១៨៣ ដល់ ១៨៧ នៃក្រមថ្មីនេះមានពិគ្រោះឧក្រិដ្ឋកម្មប្រល័យពូជសាសន៍។ ការអនុម័តនូវច្បាប់ដាក់ប្រកាសអោយប្រើនៅក្នុងឆ្នាំ ២០០៩ ពិតណាស់មិនអាចអនុញ្ញាតអោយមានការអនុវត្តប្រតិសកម្មចំពោះអនុសញ្ញាប្រល័យពូជសាសន៍ចំពោះឧក្រិដ្ឋកម្មដែលគេចោទថាបានកើតឡើងនៅក្នុងអំឡុងឆ្នាំ ១៩៧៥-៧៩។

[38] វាគួរត្រូវបានកត់សម្គាល់ថា នៅចន្លោះពីថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ និង ថ្ងៃទី៦ ខែមករា ឆ្នាំ១៩៧៩ មានរដ្ឋធម្មនុញ្ញពីរបានចូលជាធរមាន។ ក្នុងអំឡុងពេលនៃរបបសាធារណៈរដ្ឋខ្មែរ (១៩៧០-១៩៧៥) រដ្ឋធម្មនុញ្ញមួយត្រូវបានប្រកាសឱ្យប្រើនៅថ្ងៃទី១០ ខែមីនា ឆ្នាំ១៩៧២។ រដ្ឋធម្មនុញ្ញថ្មីមួយមិនត្រូវបានប្រកាសឱ្យប្រើរហូតដល់ថ្ងៃទី៥ ខែមករា ឆ្នាំ១៩៧៦ ក្នុងអំឡុងពេលនៃរបបកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩)។ *សូមមើល អត្ថបទរបស់* RAOUL M. JENNAR ក្រោមចំណងជើងថា រដ្ឋធម្មនុញ្ញកម្ពុជា (ពីឆ្នាំ ១៩៥៣ ដល់ ១៩៩៣) ទំព័រ ៥៧-៦៨ និង ៨១ (White Lotus, 1995) ។

[39] *សូមមើល តុលាការជាតិនានាចុងក្រោយចាប់ផ្តើមចោទប្រកាន់ឧក្រិដ្ឋកម្មប្រល័យពូជសាសន៍* នៅទំព័រ ៦២។ ឧទាហរណ៍ដ៏ល្អមួយអាចត្រូវបានគេឃើញតាមរយៈ ព្រឹទ្ធសមាជិកអាមេរិច William Proxmire (ស្លាប់)។ ថ្វីបើសហរដ្ឋអាមេរិចបានចុះហត្ថលេខាលើអនុសញ្ញាប្រល័យពូជសាសន៍ កាលពីថ្ងៃទី ១១ ធ្នូ ១៩៤៨ អាមេរិចមិនបានផ្តល់សច្ចាប័នដល់អនុសញ្ញានេះ ឬបង្កើតនូវច្បាប់ដាក់ប្រកាសអោយប្រើ (Implementing legislation) ដើម្បីអោយឧក្រិដ្ឋប្រល័យពូជសាសន៍នៃអាចត្រូវបានគេចោទប្រកាន់នៅសហរដ្ឋអាមេរិច រហូតដល់ថ្ងៃទី ២៥ វិច្ឆិកា ១៩៨៨។ ចាប់ផ្តើមពីឆ្នាំ ១៩៦៧ William Proxmire បានធ្វើសុន្ទរកថា រៀងរាល់ថ្ងៃនៅរាល់កិច្ចប្រជុំសភា ដែលជាសរុបមានចំនួន ៣២១១ សុន្ទរកថា អំឡុងពេលជាង ២១ ឆ្នាំ ក្រោយមករដ្ឋាភិបាលសហរដ្ឋអាមេរិចបានផ្តល់សច្ចាប័នដល់អនុសញ្ញានេះ និងអនុម័តនូវច្បាប់ដាក់ប្រកាសអោយអនុសញ្ញាប្រល័យពូជសាសន៍របស់ Proxmire ផ្ទាល់។ *សូមមើល* Wisconsin Historical Society website គេហទំព័រដែលអាចរកបាននៅ http://www.wisconsinhistory.org/turningpoints/search.asp?id=1512.

ពីថ្ងៃទី ១៤ តុលា ១៩៥០[40] ក៏ដោយ ក៏ហាក់ដូចជាថា ប្រទេសកម្ពុជាមិនមែនជាភាគីមួយទៅនឹងអនុសញ្ញានេះទេ នៅក្នុងអំឡុងពេលនោះ ហេតុដូច្នេះ អនុសញ្ញានេះមិនអាចយកមក អនុវត្តបានទេ។ ចំនុចត្រង់នេះគឺដោយសារ ប្រទេសកម្ពុជាបានយល់ព្រមទទួលយកអនុសញ្ញានេះ នៅពេលដែលខ្លួនស្ថិតនៅក្រោមអាណានិគមបារាំងនៅឡើយ។ ប្រទេសកម្ពុជាបានទទួលឯករាជ្យរបស់ខ្លួននៅថ្ងៃ ៩ វិច្ឆិកា ១៩៥៣[41]។ "អនុសញ្ញានេះមិនមាននិយាយទាំងអស់អំពីវិធានទាំងឡាយដែលអាចអនុវត្តចំពោះរដ្ឋទាយាទ/រដ្ឋដែលឡើងកាន់កាប់ដំណែងបន្តពីរដ្ឋមុន (State succession)[42]"។ ក្នុងស្ថានភាពបែបនេះ វិធានទូទៅដែលត្រូវបានគេសំអាងថាជា គោលការណ៍ "clean slate" គឺថាបណ្តារដ្ឋឯករាជ្យថ្មីៗមិនក្លាយជាភាគីមួយទៅនឹងអនុសញ្ញាណាមួយ ដោយសារតែត្រឹមតែហេតុផលមួយថា អនុសញ្ញានេះបានចូលជាធរមាននៅមុនកាលបរិច្ឆេទឡើងស្នងបន្តនោះ[43]។ មានការជំទាស់តវ៉ាថា មិនគួរយកគោលការណ៍នេះមកអនុវត្តចំពោះអនុសញ្ញាទាំងឡាយស្តីពីសិទ្ធិមនុស្សនោះទេ ប៉ុន្តែ បញ្ហានេះមិនទាន់បានដោះស្រាយនៅឡើយនោះទេ[44]។ បើទោះបីប្រទេសកម្ពុជាបានសំអាងទៅលើអនុសញ្ញានេះដែលនៅមុនអំឡុងពេលនៃកម្ពុជាប្រជាធិបតេយ្យ (ដែលស្ថិតនៅ

---

[40] *សូមមើល* http://treaties.un.org/Pages/ViewDetails.aspx?src=UNTSONLINE&tabid=2&mtdsg_no=IV-1&chapter=4&lang=en#Participants. ប្រសិនបើអនុសញ្ញានោះមិនកំណត់តាមបែបផ្សេងទេ នោះការចូលរួមមានប្រសិទ្ធភាពដូចគ្នាទៅនឹងការផ្តល់សច្ចាប័នដែរ។ *សូមមើល* AUST នៅទំព័រ ៩០។

[41] *សូមមើល* Kenneth T. So, *The Road to Khmer Independence*, មាននៅមជ្ឈមណ្ឌលព័ត៌មានកម្ពុជា, http://www.cambodia.org/facts/?page=independence.

[42] អំពើប្រល័យពូជសាសន៍នៅក្នុងច្បាប់អន្តរជាតិ (GENOCIDE IN INTERNATIONAL LAW), ទំព័រ ៥០៨ ។

[43] MALCOLM N. SHAW QC, INTERNATIONAL LAW 882 (ប្រែសម្រួលលើកទី៥ ឆ្នាំ២00៣) ។ អត្ថបទរបស់ JAMES CRAWFORD ស្តីពី ការបង្កើតរដ្ឋនៃច្បាប់អន្តរជាតិ 309 (Oxford University Press, 2000)។ វិធានទូទៅនេះត្រូវបានកែប្រែនៅក្នុងមាត្រា ១៦ នៃអនុសញ្ញាទីក្រុងវីយែនស្តីពីរដ្ឋស្នងបន្ត ទាក់ទងនឹងសន្ធិសញ្ញានេះ ដែលបានចូលជាធរមាននៅថ្ងៃទី ៦ វិច្ឆិកា ១៩៩៦។ អង្គការសហប្រជាជាតិ *Treaty Series*, vol. 1946ទំព័រ ៣។

[44] ប្រទេសស៊ែប៊ី (Serbia) បានសួរថាតើប្រទេសបូស្នៀ (Bosnia) គឺជាភាគីមួយនៃអនុសញ្ញាប្រឆាំងនឹងអំពើប្រល័យពូជសាសន៍ដែរឬយ៉ាងណា នៅក្នុងរឿងក្តីនៅចំពោះមុខតុលាការយុត្តិធម៌អន្តរជាតិ ("ICJ"), ប៉ុន្តែ ICJ បានបដិសេធមិនទទួលយកគោលជំហរផ្លូវការទៅលើបញ្ហានោះទេ។ អំពើប្រល័យពូជសាសន៍នៅក្នុងច្បាប់អន្តរជាតិ (GENOCIDE IN INTERNATIONAL LAW, AT 509) ។ "ហេតុដូច្នេះ បញ្ហានៃពាក្យ៖ ការអនុវត្តបន្តនៃសន្ធិសញ្ញាសិទ្ធិមនុស្ស នៅក្នុងដែនកំណត់នៃរដ្ឋមុន ដោយមិនគិតដល់ការទទួលបន្ត គឺពិតជាស្ថិតក្រោមការពិចារណាដ៏ច្បាស់លាស់។ ថាតើគោលការណ៍នេះត្រូវបានបង្កើតឡើងនៅពេលបច្ចុប្បន្នមិនច្បាស់លាស់យ៉ាងណានោះ" សូមមើល MALCOLM N. SHAW QC, INTERNATIONAL LAW 889 (ប្រែសម្រួលលើកទី៥ ឆ្នាំ២00៣)។

ក្រោយយុត្តាធិការពេលវេលារបស់ អវតក) [45] ដែលហាក់ចង់បង្ហាញឲ្យឃើញថាប្រទេសកម្ពុជាខ្លួនឯងបានជាប់កាតព្វកិច្ចទៅនឹងអនុសញ្ញានេះក៏ដោយ ក៏ការសំអាងនេះមិនបានកើតឡើងឡើយរហូតទាល់ដល់ក្រោយអំឡុងពេលនៃបញ្ហានោះ។ ការដែលប្រទេសកម្ពុជាមិនបាននិយាយយោងទៅអនុសញ្ញានេះ នៅចន្លោះពីពេលទទួលបានឯករាជ្យភាព និង ចុងបញ្ចប់នៃរបបកម្ពុជាប្រជាធិបតេយ្យ ហើយដែលខ្លួនមិនបានអនុម័តច្បាប់ដាក់ប្រកាសអោយប្រើណាមួយ ដើម្បីផ្តល់អានុភាពដល់អនុសញ្ញានេះ ស្តែងឲ្យឃើញថា ប្រទេសកម្ពុជាមិនបានពិចារណាថា ខ្លួនជាប់កាតព្វកិច្ចនោះទេ។ ប្រសិនបើប្រទេសកម្ពុជាមិនជាប់កាតព្វកិច្ចទៅនឹងអនុសញ្ញាប្រឆាំងនឹងអំពើប្រល័យពូជសាសន៍ នៅក្នុងអំឡុងពេលពីឆ្នាំ ១៩៧៥-១៩៧៩ ទេ នោះឧក្រិដ្ឋកម្មដែលត្រូវបានចោទប្រកាន់ថាបានកើតឡើងនៅក្នុងពេលនោះ មិនអាចត្រូវបានផ្តន្ទាទោសដោយសំអាងទៅលើអនុសញ្ញានេះបានឡើយ។

២៤. អនុសញ្ញាប្រឆាំងនឹងអំពើប្រល័យពូជសាសន៍ មិនអាចធ្វើជាមូលដ្ឋានសម្រាប់ការផ្តន្ទាទោសពីសំណាក់តុលាការជាតិនៅក្នុងប្រទេសកម្ពុជាបានឡើយ ដោយហេតុថា ប្រទេសកម្ពុជាមិនមានច្បាប់ដាក់ប្រកាសអោយប្រើអនុសញ្ញានេះ នៅពេលដែលឧក្រិដ្ឋកម្មទាំងនេះត្រូវបានចោទប្រកាន់ថាកើតមានឡើង ហើយរដ្ឋធម្មនុញ្ញកម្ពុជាក៏មិនបានអនុញ្ញាតឲ្យមានការអនុវត្តដោយផ្ទាល់របស់អនុសញ្ញាប្រល័យពូជសាសន៍នោះដែរ។ ដូចគ្នានេះដែរ អនុសញ្ញាប្រឆាំងនឹងអំពើប្រល័យពូជសាសន៍ មិនអាចជាមូលដ្ឋានសម្រាប់ការផ្តន្ទាទោសពីសំណាក់តុលាការជាតិបានទេ ប្រសិនបើអនុសញ្ញានេះមិនបានចូលជាធរមាន នៅពេលដែលឧក្រិដ្ឋកម្មទាំងនោះត្រូវបានប្រព្រឹត្តឡើងនោះទេ។

### ii. ច្បាប់ទំនៀមទម្លាប់អន្តរជាតិ រួមទាំង *វិធានអាជ្ញាបញ្ញា* មិនអាចយកមកអនុវត្តនៅក្នុងតុលាការកម្ពុជាដោយផ្ទាល់បាននោះទេ

#### ១. តុលាការកម្ពុជាមិនអាចយកច្បាប់ទំនៀមទម្លាប់អន្តរជាតិមកអនុវត្តដោយផ្ទាល់បានទេ

២៥. ច្បាប់ទំនៀមទម្លាប់អន្តរជាតិ ដែលផ្តន្ទាទោសចំពោះឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ មិនអាចអនុវត្ត

[45] ឧទាហរណ៍ អនុសញ្ញាប្រឆាំងនឹងអំពើប្រល័យពូជសាសន៍ ត្រូវបានយោងទៅនឹងក្រឹត្យច្បាប់ (Decree Laws) លេខ១ មាត្រា៨។ ទោះជាយ៉ាងណា ច្បាប់ទាំងនេះត្រូវបានអនុម័តក្រោយចុងបញ្ចប់នៃអំឡុងពេលដែល អ.វ.ត.ក មានយុត្តាធិការ។ *សូមមើល ឧក្រិដ្ឋកម្មប្រល័យពូជសាសន៍នៅកម្ពុជា* DOCUMENTS FROM THE TRIAL OF POL POT AND IENG SARY 47 (Howard J. De Nike, John Quigley & Kenneth J. Robinson eds., University of Pennsylvania Press, 2000).

នៅក្នុងតុលាការកម្ពុជាដោយផ្ទាល់បានទេ។ នោះពេលណាដែលច្បាប់ទំនៀមទម្លាប់អន្តរជាតិត្រូវបានយកសំអាងនៅក្នុងតុលាការជាតិ នោះតុលាការជាតិត្រូវពិចារណា ប្រសិនបើ និងនៅក្រោមកាលៈទេសៈណា ដែលប្រព័ន្ធច្បាប់ជាតិរបស់ខ្លួនបើកចំហអោយមានការអនុវត្តច្បាប់ទំនៀមទម្លាប់អន្តរជាតិបាន។ អវត្តមាននៃសេចក្តីណែនាំជាក់លាក់នៅក្នុងរដ្ឋធម្មនុញ្ញ ច្បាប់ ឬ យុត្តិសាស្ត្រជាតិរបស់ខ្លួនទេនោះ តុលាការជាតិមិនមានកាតព្វកិច្ចអនុវត្តច្បាប់ទំនៀមទម្លាប់អន្តរជាតិទេ[46]។ ដោយហេតុថា ប្រទេសកម្ពុជាប្រកាន់យកនូវប្រព័ន្ធទ្វិកនិយម (dualist system) នោះរដ្ឋធម្មនុញ្ញ ឬច្បាប់ជាតិរបស់កម្ពុជា ត្រូវតែមានចែងអំពីវិធាននៃទំនៀមទម្លាប់អន្តរជាតិ ដើម្បីអាចយកមកអនុវត្តនៅក្នុងវិស័យរបស់ជាតិ មុននឹងយកច្បាប់អន្តរជាតិនេះមកអនុវត្តបាន។

២៦. ទាំងរដ្ឋធម្មនុញ្ញដែលចូលជាធរមាន នៅពេលដែលឧក្រិដ្ឋកម្មទាំងនោះត្រូវបានចោទប្រកាន់ថាបានប្រព្រឹត្តឡើង មិនដែលបានចែងពីនីតិវិធីស្តីពីការដាក់បញ្ចូលច្បាប់ទំនៀមទម្លាប់អន្តរជាតិ ទៅក្នុងច្បាប់ជាតិនោះឡើយ។ ហើយរដ្ឋសភាជាតិកម្ពុជាក៏មិនដែលបានអនុម័តច្បាប់ណាមួយដោយមានការបញ្ជាក់ឱ្យបានច្បាស់លាស់ អំពីការដាក់បញ្ចូលវិធានណាមួយនៃច្បាប់ទំនៀមទម្លាប់អន្តរជាតិ ដែលទាក់ទងទៅនឹងអំពើប្រល័យពូជសាសន៍ ទៅក្នុងប្រព័ន្ធច្បាប់ជាតិរបស់ខ្លួននោះដែរ។ បន្ថែមទៅលើការដែលថា ការអនុវត្តន៍ដោយផ្ទាល់នូវច្បាប់ទំនៀមទម្លាប់អន្តរជាតិ ត្រូវបានហាមឃាត់នៅក្នុងប្រព័ន្ធច្បាប់កម្ពុជានោះ គោលការណ៍៖ *គ្មានបទល្មើសទេ បើគ្មានច្បាប់ចែង* (*nullum crimen sine lege*) នៅក្នុងករណីនេះ រាំងចំពោះការយកច្បាប់ទំនៀមទម្លាប់អន្តរជាតិមកអនុវត្តដោយផ្ទាល់ទៅក្នុងប្រព័ន្ធច្បាប់ជាតិ[47]។

---

[46] *សូមមើល* ANTONIO CASSESE, INTERNATIONAL CRIMINAL LAW 303 (Oxford University Press 2003) [បន្ទាប់ពីនេះយោងដោយ CASSESE] "ជាធម្មតា តុលាការជាតិមិនដំណើរការនីតិវិធីរឿងក្តី សម្រាប់ឧក្រិដ្ឋកម្មអន្តរជាតិទេ តែឈរលើមូលដ្ឋានច្បាប់*ទំនៀមទម្លាប់*អន្តរជាតិ គឺថា ប្រសិនបើឧក្រិដ្ឋកម្មមួយត្រូវបានកំណត់ក្នុងន័យនៃច្បាប់នោះ។ ជាជំនួសពួកគេទំនងជា លក្ខន្តិកៈជាតិដែលកំណត់ឧក្រិដ្ឋកម្ម និងផ្តល់យុត្តាធិការឱ្យតុលាការជាតិទៅលើលក្ខន្តិកៈនោះ ឬ ប្រសិនបើសន្ធិសញ្ញាមួយត្រូវបានផ្តល់សច្ចាប័នលើបញ្ហានោះដោយរដ្ឋ ការអនុម័តនៃ *ច្បាប់ស្តីពីការអនុវត្តន៍* អាចឱ្យតុលាការអនុវត្តពេញលេញនូវបទប្បញ្ញត្តិសន្ធិសញ្ញាដែលជាប់ទាក់ទង"។ (គូសបញ្ជាក់ក្នុងច្បាប់ដើម)។ *សូមមើលផងដែរ រឿងក្តី U.S. តទល់ Yousef*, 327 F.3d 56, 91 (2nd Cir. 2003) "ច្បាប់សហរដ្ឋអាមេរិកមិនស្ថិតក្រោមច្បាប់ទំនៀមទម្លាប់អន្តរជាតិទេ ឬចាំបាច់ស្ថិតក្រោមច្បាប់អន្តរជាតិដែលពឹងផ្អែកលើសន្ធិសញ្ញានោះទេ ហើយតាមពិតនោះ អាចប្រឆាំងគ្នាទាំងពីរទៀតផង"។

[47] "គោលការណ៍ប្រទាក់គ្នា[ពីរ] នៃភាពគ្មានបទល្មើសបើមិនមានច្បាប់ចែង (*nullum crimen sine lege*) និងភាពជាក់លាក់ផ្លូវច្បាប់ ជាទូទៅ ត្រូវបានចាត់ទុកថាសំខាន់ខ្លាំងចំពោះរបៀបរៀបរយផ្នែកច្បាប់ ដែលគោលការណ៍ទាំងពីរនេះការពារយ៉ាងមានប្រសិទ្ធភាពមិនឱ្យដាក់បញ្ចូលក្នុងច្បាប់ឧក្រិដ្ឋកម្មក្នុងស្រុក សូម្បីតែតាមវិធីនៃការបកស្រាយនៃវិធានទំនៀមទម្លាប់ដែល

២៧. តុលាការនៃប្រទេសបារាំង ដែលប្រព័ន្ធច្បាប់របស់ខ្លួនត្រូវបានប្រព័ន្ធច្បាប់កម្ពុជាយកមកធ្វើជាគំរូ តាមបានយល់ឃើញថា ច្បាប់ទំនៀមទម្លាប់អន្តរជាតិមិនអាចយកមកអនុវត្តនៅក្នុងតុលាការប្រទេសបារាំងដោយផ្ទាល់បានទេ ដោយសារតែកង្វះបទប្បញ្ញត្តិជាលាយលក្ខណ៍អក្សរ នៅក្នុងយុត្តាធិការរបស់បារាំងក្នុងការចាត់ទុកថាអំពើដែលពាក់ព័ន្ធជាបទល្មើស។ ជាឧទាហរណ៍ នៅក្នុងរឿងក្ដីរវាង *Rapporteurs sans Frontières* *តទល់នឹង* *Mille Collines* សាលាឧទ្ធរណ៍នៃប្រទេសបារាំងបានលើកឡើងថា ខ្លួនខ្វះយុត្តិសាស្ត្រសម្រាប់បទល្មើសអន្តរជាតិផ្សេងៗ ដែលបានប្រព្រឹត្តឡើងដោយជនបរទេស នៅឯក្រៅប្រទេស ដោយសារតែ "ការអវត្តមានច្បាប់ជាតិ នោះទំនៀមទម្លាប់អន្តរជាតិ មិនអាចមានអានុភាពក្នុងការពង្រីកយុត្តាធិការក្នុងលំហរ (extraterritorial jurisdiction) របស់តុលាការប្រទេសបារាំងបានឡើយ"[48]។

២៨. វិធីសាស្ត្រស្រដៀងគ្នាមួយ ដែលច្រានចោលការអនុវត្តច្បាប់ទំនៀមទម្លាប់អន្តរជាតិដោយផ្ទាល់ ត្រូវបានអនុវត្តតាមដោយតុលាការកំពូលប្រទេសហូឡង់ នៅក្នុងរឿងក្ដី *Bouterse* ដែលបានសម្រេចជំទាស់ទៅនឹងការអនុវត្តន៍ច្បាប់ទំនៀមទម្លាប់ដោយផ្ទាល់ ថាជាមូលដ្ឋានសម្រាប់ការចោទប្រកាន់អំពើល្មើសអន្តរជាតិ នៅក្នុងតុលាការជាតិ។ សាលដីកានេះបានលើកឡើងថា ការអនុវត្តន៍ដោយផ្ទាល់បែបនេះអាចនាំឱ្យមានការគំរាមកំហែងដល់ទ្រឹស្ដីដែលថា *គ្មានបទល្មើសទេ បើគ្មានច្បាប់ចែង* (*nullum crimen sine lege*)[49]។ ការយល់ឃើញប្រហាក់ប្រហែលគ្នានេះ ត្រូវបានធ្វើឡើងដោយតុលាការប្រទេសអាឡឺម៉ង់[50] ប្រទេសស្វីស[51] និងប្រទេសមួយចំនួនទៀត។ វិទ្យាស្ថាន

---

មិនមានចែងជាលាយលក្ខណ៍អក្សរក៏ដោយ។ ... ដូច្នេះការអនុម័តច្បាប់ស្ដីពីការអនុវត្តន៍ គឺជាតម្រូវការសកល សម្រាប់ការអនុវត្តន៍គោលការណ៍ច្បាប់ឧក្រិដ្ឋកម្មអន្តរជាតិណាមួយ ក្នុងរបៀបរៀបរយផ្នែកច្បាប់ជាតិ" (គូសបញ្ជាក់បន្ថែម)។ Simonetta Stirling-Zanda, *The Determination of Customary International Law in European Courts (France, Germany, Italy, The Netherlands, Spain, Switzerland)*, 4 NON STATE ACTORS AND INT'L L. 3, 6 (2004) (គូសបញ្ជាក់បន្ថែម)។

48 Gabriele Olivi, *The Role of National Courts in Prosecuting International Crimes: New Perspectives*, 18 SRI LANKA J. INT'L L. 83, 87 (2006) *ដកស្រង់ រឿងក្ដី* *Reportiers sans Frontières* *តទល់នឹង* *Mille Collines*, សាលាឧទ្ធរណ៍ក្រុង Paris, សាលក្រម, ចុះថ្ងៃទី៦ ខែវិច្ឆិកា ឆ្នាំ១៩៩៥ នៅទំព័រ ៤៨-៥១។

49 FERDINANDUSSE, ទំព័រ៦៩។

50 គោលការណ៍នីត្យានុកូលភាពក្នុងច្បាប់អាល្លឺម៉ង់ ជាក់ស្ដែងមិនរាប់បញ្ចូលការអនុវត្តន៍ដោយផ្ទាល់ទូទៅ នៃបទល្មើសអន្តរជាតិទាំងអស់ ថាតើបទល្មើសទាំងនោះមាននៅក្នុងទំនៀមទម្លាប់ ឬអនុសញ្ញាយ៉ាងណានោះទេ ។ ដូចយោងខាងលើ ទំព័រ៤០។

51 សាលាឧទ្ធរណ៍យោធាប្រទេស Swiss បានលើកឡើងក្នុងឆ្នាំ២000 ថា ទំនៀមទម្លាប់ឧក្រិដ្ឋតួបនីយកម្មនៃអំពើប្រល័យពូជសាសន៍មិនអាចអនុវត្ត ដោយមិនមានវិធានច្បាស់លាស់នៃសំអាងដែលអនុញ្ញាតឱ្យមានការអនុវត្តរបស់ខ្លួននៅពេលដែលអំពើដែលបានចោទប្រកាន់ ត្រូវបានប្រព្រឹត្តឡើង។ *ដូចជើងទំព័រខាងលើ ទំព័រ* ៤0-៤១។

Max Planck បានធ្វើការសិក្សាស្រាវជ្រាវមួយដែលមានចំណងជើងថា *ការផ្តន្ទាទោសបទល្មើសអន្តរជាតិដោយតុលាការជាតិ*។ ឯកសារពិភាក្សាពីលទ្ធផលនៃការសិក្សានេះបានបង្ហាញថា៖

> គ្មានប្រទេសណាមួយដែលស្ថិតនៅក្រោមការត្រួតពិនិត្យ [៣៥ រដ្ឋ] នៅក្នុងគម្រោង MPI ជ្រើសរើសយកការផ្តន្ទាទោសអ្នកប្រព្រឹត្តអំពើប្រល័យពូជសាសន៍ ដោយគ្រាន់តែអនុវត្តច្បាប់ព្រហ្មទណ្ឌអន្តរជាតិទំនៀមទម្លាប់តែមួយមុខនោះទេ។ ក្នុងវិធីផ្សេងៗគ្នា បទប្បញ្ញត្តិច្បាប់ព្រហ្មទណ្ឌជាតិ ត្រូវបានតម្រូវឱ្យយកមកធ្វើមូលដ្ឋានសម្រាប់ការផ្តន្ទាទោសដោយតុលាការជាតិ[52]។

២៩. ជាទូទៅ ការពិភាក្សាយ៉ាងល្អិតល្អន់ទៅលើការអនុវត្តន៍ច្បាប់ទំនៀមទម្លាប់អន្តរជាតិនៅក្នុងប្រទេសកម្ពុជា និងប្រទេសដទៃទៀត[53] បង្ហាញឱ្យឃើញថា កសចស មិនត្រូវបានគេផ្តល់អំណាចអោយអនុវត្តច្បាប់ទំនៀមទម្លាប់អន្តរជាតិដោយផ្ទាល់ ក្នុងពេលមិនមានច្បាប់ជាតិដាក់ប្រកាសអោយប្រើនោះទេ។ ច្បាប់ទំនៀមទម្លាប់អន្តរជាតិនឹងអាចអនុវត្តបានដោយផ្ទាល់ នៅក្នុងប្រទេសកម្ពុជាបានតែក្នុងករណី ដែលច្បាប់នេះត្រូវបានប្រតិបត្តិយ៉ាងហ្មត់ចត់ តាមរយៈច្បាប់កម្ពុជាតែប៉ុណ្ណោះ។

៣០. សូម្បីតែឧបមាថា រដ្ឋនីមួយៗមានកាតព្វកិច្ចផ្តន្ទាទោសអំពើប្រល័យពូជសាសន៍ នៅក្រោមច្បាប់ទំនៀមទម្លាប់អន្តរជាតិ ហើយនេះជាកាតព្វកិច្ចដែលមិនបានដោះស្រាយឱ្យបានច្បាស់លាស់[54] ករណីយកិច្ចនេះមិនដាក់បន្ទុកដល់ កសចស នោះទេ ប៉ុន្តែ ជាបន្ទុករបស់រដ្ឋាភិបាលកម្ពុជា ទៅវិញទេ។ នៅក្នុងបណ្តាសង្គមប្រជាធិបតេយ្យ "បទល្មើសព្រហ្មទណ្ឌត្រូវបានកំណត់យ៉ាងច្បាស់ដោយអង្គនីតិប្រតិបត្តិ។ តុលាការខ្លួនឯងមិនអាចសម្រេចអំពីអត្ថិភាពនៃ *បទល្មើសមួយជាថ្មី* (de novo)

---

[52] *សូមមើល* Helmut Kreicker, *National Prosecution of Genocide from a Comparative Perspective*, 5 INT'L CRIM. L. REV. 313, 320 (2005) ។

[53] *សូមមើល* ឧបសម្ព័ន្ធ ខ ភ្ជាប់នឹង *រឿងក្តី អៀង សារី* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អ.វ.ត.ក/ក.ស.ច.ស សេចក្តីសង្កេតបន្ថែមរបស់លោក អៀង សារី ស្តីពីការអនុវត្តទ្រឹស្តីសហកម្មឧក្រិដ្ឋកម្មរួម នៅ អ.វ.ត.ក ចុះថ្ងៃទី២៤ ខែវិច្ឆិកា ឆ្នាំ២០០៨ ចំពោះសេចក្តីអត្ថាធិប្បាយរួម ស្តីពីការអនុវត្តន៍ច្បាប់ទំនៀមទម្លាប់អន្តរជាតិ នៅក្នុងតុលាការជាតិ។

[54] "ក្រៅពីមិនមានវិធានទំនៀមទម្លាប់ ជាមួយនឹងមាតិកាទូទៅ មិនមានគោលការណ៍អន្តរជាតិអាចត្រូវបានរកឃើញថាអាចប្រហែលជាត្រូវសំអាងទៅលើ ដើម្បីបញ្ជាក់ថាកាតព្វកិច្ចក្នុងការកាត់សេចក្តីឧក្រិដ្ឋកម្មអន្តរជាតិ បានធ្វើឱ្យច្បាស់ឡើងក្នុងសហគមន៍អន្តរជាតិ"។ CASSESE, ទំព័រ៣០២។

ដែលមិនបានចែងនៅក្នុងច្បាប់ ដែលត្រូវបានប្រកាសឱ្យប្រើដោយអង្គនីតិប្រតិបត្តិនោះទេ”[55]។ ហេតុដូច្នេះ កាតព្វកិច្ចតាមការសន្ធតណាមួយនៃច្បាប់ទំនៀមទម្លាប់អន្តរជាតិក្នុងការផ្តន្ទាទោសអំពើប្រល័យពូជសាសន៍ គឺជាភារៈរបស់ប្រទេសកម្ពុជា ក្នុងនាមជារដ្ឋមួយ មិនមែនជាបន្ទុករបស់ ក.ស.ច.ស នោះឡើយ។

**២. ការដែលអំពើប្រល័យពូជសាសន៍ត្រូវបានសំអាងថាទទួលបានឋានៈជា វិធានអាជ្ញាបញ្ញា (*jus cogens*) មិនមានន័យថា គេអាចយកវាមកអនុវត្តដោយផ្ទាល់បាននៅក្នុងតុលាការកម្ពុជានោះទេ**

៣១. *វិធានដាច់ខាត* (*Jus cogens*) ត្រូវបានឱ្យនិយមន័យថាជា “វិធាននៃច្បាប់ទំនៀមទម្លាប់ ដែលមិនអាចបដិសេធចោលដោយសន្ធិសញ្ញា ឬតាមការស្រុះស្រួលនោះទេ ប៉ុន្តែ តាមរយៈការបង្កើតវិធានទំនៀមទម្លាប់បន្តបន្ទាប់មួយផ្សេងពីនេះតែប៉ុណ្ណោះ”[56]។ តុលាការយុត្តិធម៌អន្តរជាតិបានទទួលស្គាល់ថា ឧក្រិដ្ឋកម្មប្រល័យពូជសាសន៍គឺជា បទដ្ឋានដាច់ខាត*ដែលមានលក្ខណៈជាវិធានអាជ្ញា*នៃច្បាប់អន្តរជាតិ (*jus cogens* peremptory norm) តាំងពីដើមទសវត្សឆ្នាំ ១៩៥១ មកម្ល៉េះ[57]។ យ៉ាងណាក៏ដោយ ចរិតជា*វិធានអាជ្ញាបញ្ញា* នៃឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ <u>មិនកែប្រែ</u>បញ្ហាដែលថា ច្បាប់ទំនៀមទម្លាប់អន្តរជាតិ មិនអាចយកមកអនុវត្តនៅក្នុងតុលាការកម្ពុជាដោយផ្ទាល់បានទេ។

> ការអនុវត្តនៅកម្រិតជាតិ និងអន្តរជាតិ ទាក់ទងទៅនឹងផលវិបាកច្បាប់ជាតិនៃបទដ្ឋានដាច់ខាត (peremptory norm) របស់ច្បាប់អន្តរជាតិ ត្រូវបានគេព្យាយាមបែងចែក ហើយជាញឹកញាប់តែងតែមិនច្បាស់ និងបានផ្តល់ហេតុផលពិបាកទទួលយកបាន។ កង្វះការវិភាគ និងកំហុសជាក់ស្តែងនៅក្នុងសាលក្រម/សាលដីកាជាច្រើន ជាពិសេស សាលក្រម/សាលដីការបស់តុលាការជាតិ បានកាត់បន្ថយតម្លៃអំណាច

---

[55] *សូមមើល* អត្ថបទរបស់ Ilias Bantekas, ក្រោមចំណងជើងថា *Reflections on Some Sources and Methods of International Criminal and Humanitarian Law,* 6 INT'L CRIM. L. REV. 121, 125 (2006) ។

[56] IAN BROWNLIE, PRINCIPLES OF PUBLIC INTERNATIONAL LAW 510 (Oxford University Press, ប្រែសម្រួលលើកទី៧ ឆ្នាំ២00៨)

[57] *ការទុកបម្រុងអនុសញ្ញាស្តីពីការការពារ និងការផ្តន្ទាទោស នៃអំពើប្រល័យពូជសាសន៍* (យោបល់ណែនាំ) របាយការណ៍ ICJ 15 (1951), ទំព័រ២៣។ លទ្ធិសិស្ស និងយោបល់តុលាការ បានគាំទ្រថា អង្គនៃបទដ្ឋានសមរម្យ *វិធានអាជ្ញាបញ្ញា (jus cogens),* បង្កើតគោលការណ៍លើសលុបនៃច្បាប់អន្តរជាតិ។

របស់សាលក្រម/សាលដីកាទាំងនោះយ៉ាងច្រើន។ និន្នាការប្រយ័ត្នប្រយែងមួយត្រូវបានគេទទួលស្គាល់ថា ជាការទទួលយកជំហរឯកសិទ្ធិចំពោះបទដ្ឋាននានានៃ *វិធានអាជ្ញាបញ្ញា* (*jus cogens* norms) នៅក្នុងប្រព័ន្ធច្បាប់ជាតិ ប៉ុន្តែ ការមិនមានការអនុវត្តដ៏រឹងមាំរបស់រដ្ឋ នោះវិធានឆ្លើយតបនៃច្បាប់ទំនៀមទម្លាប់អន្តរជាតិ ហាក់ដូចជាមាននៅក្នុងដំណាក់កាលបង្កើតឡើង (ថ្មីៗ) តែប៉ុណ្ណោះ[58]។

៣២. ការនិយាយថាអំពើប្រល័យពូជសាសន៍ជា *វិធានអាជ្ញាបញ្ញា* (*Jus cogens*) មានន័យថា រដ្ឋនីមួយៗមានកាតព្វកិច្ចមិនចូលរួមនៅក្នុងអំពើប្រល័យពូជសាសន៍ទេ។ ឋានៈដាច់ខាត (peremtory) នៃកាតព្វកិច្ចឆ្លើយតបដើម្បីផ្តន្ទាទោសមិនទាន់បានដោះស្រាយនៅឡើយទេ[59]។ ឋានៈនៃអំពើប្រល័យពូជសាសន៍ដែលមានលក្ខណៈជា *បទដ្ឋានដាច់ខាត* <u>អាច</u>ប៉ះពាល់ដល់លទ្ធភាពរបស់រដ្ឋ ក្នុងការប្រើប្រាស់នូវយុត្តាធិការក្នុងលំហ (extraterritorial jurisdiction) <u>ប្រសិនបើ</u>រដ្ឋនោះជ្រើសរើសធ្វើបែបនោះ ប៉ុន្តែ <u>នឹងមិន</u>អនុញ្ញាតឱ្យរដ្ឋមានយុត្តាធិការដូចខាងលើនោះទេ <u>ប្រសិនបើ</u>រដ្ឋនោះមានកង្វះខាតផ្សេងពីនេះ[60]។

---

[58] FERDINANDUSSE, ទំព័រ១៦៩។

[59] *ដូចជើងទំព័រខាងលើ* ទំព័រ ១៨២-៨៥។ *សូមមើលផងដែរ* Michael Scharf, *From the Exile Files: អត្ថបទស្តីពីយុត្តិធម៌ពាណិជ្ជកម្ម សម្រាប់សន្តិភាព (Trading Justice for Peace)*, 63 WASH. & LEE L. REV. 339, 364-367 (2006), ពិភាក្សាអំពី *វិធានអាជ្ញាបញ្ញា (jus cogens)* ប្រភេទនៃឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ និងកាតព្វកិច្ចរដ្ឋ៖ "ទោះបីជាមិនមានបញ្ហាដែលថាសមាគមន៍អន្តរជាតិបានទទួលយកថា ការរារាំងប្រឆាំងនឹងការប្រព្រឹត្ត ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិចាត់ទុកជាបទដ្ឋាន *វិធានអាជ្ញាបញ្ញា (jus cogens)* បញ្ហានេះមិនមានន័យថាកិច្ចការ ដែលជាប់ពាក់ព័ន្ធត្រូវកាត់ទោសបានទទួលឋានៈសមមូលដំណាលគ្នា។ តាមពិត ភស្តុតាងទាំងអស់គឺផ្ទុយទៅវិញទេ"។

[60] ឧទាហរណ៍ ស្ថានភាពនេះបានកើតឡើងនៅ Netherlands ។ "លក្ខន្តិកៈក្នុងស្រុកគឺ … ចាំបាច់ដើម្បី 'ប្រែក្លាយ' កាតព្វកិច្ចច្បាប់អន្តរជាតិ ទៅក្នុងច្បាប់ព្រហ្មទណ្ឌ Dutch។ តុលាការព្រហ្មទណ្ឌ Dutch មិនអាចអនុវត្តច្បាប់អន្តរជាតិដោយផ្ទាល់ដោយមិនមានការផ្លាស់ប្តូរនោះទេ។ លើសនេះទៀត, ឧក្រិដ្ឋកម្មអន្តរជាតិដែលជាប់ទាក់ទង ត្រូវតែបានផ្លាស់ប្តូរក្នុងវិធីនេះនៅពេលដែលពួកគេបានប្រព្រឹត្ត។ <u>វិធាននេះក៏អនុវត្តផងដែរ ទៅលើកាតព្វកិច្ចសន្ធិសញ្ញា សូម្បីតែកន្លែងដែលពួកវាតំណាងឱ្យបទដ្ឋាន</u> *វិធានអាជ្ញាបញ្ញា (jus cogens)*"។ Pita Schimmelpennick van der Oije & Steven Freeland, *យុត្តាធិការសកលនៅ Netherlands – វិធីត្រឹមត្រូវ ប៉ុន្តែក្នុងករណីខុស? Bouterse និង 'December Murders'*, 20 AUSTL. J. HUM. RTS. (2001) មាននៅ៖ http://www.austlii.edu.au/au/journals/AJHR/2001/20.html (ការទាញហេតុសំអាងខាងក្នុងត្រូវបានលុប) (គូសបញ្ជាក់បន្ថែម)។

៣៣. ឧទាហរណ៍មួយនៃករណីនេះអាចរកបាននៅក្នុងរឿងក្ដីរបស់ *Bagaragaza*[61] នៅ ICTR។ ក្នុងរឿងក្ដីដែលជនជាប់ចោទត្រូវបានចោទប្រកាន់ពីបទប្រល័យពូជសាសន៍បែបនេះ អង្គជំនុំជម្រះសាលាដំបូងបានច្រានចោលសំណើរបស់ព្រះរាជអាជ្ញា ក្នុងការស្នើសុំបញ្ជូនដីកាចោទប្រកាន់ទៅឲ្យចក្រភពណ័រវេយ ដោយការលើកឡើងថា ទោះបីជាប្រទេសណ័រវេយបានផ្ដល់សច្ចាប័នទៅលើអនុសញ្ញាប្រឆាំងនឹងអំពើប្រល័យពូជសាសន៍ កាលពីថ្ងៃទី២២ កក្កដា ១៩៩៤ រួចទៅហើយក្ដី ក៏ច្បាប់ព្រហ្មទណ្ឌជាតិរបស់ប្រទេសនេះ មិនមានបទប្បញ្ញត្តិណាមួយចែងពីការផ្ដន្ទាទោសអំពើប្រល័យពូជសាសន៍នោះទេ[62]។ បញ្ហាគឺ ថាតើប្រទេសណ័រវេយមានយុត្តាធិការ *ratione materiae* ដែរឬយ៉ាងណានោះ។ អង្គជំនុំជម្រះបានលើកឡើងថា ដើម្បីឲ្យខ្លួនមានលទ្ធភាពក្នុងការរកឃើញថាប្រទេសណ័រវេយអាចអនុវត្តយុត្តាធិការ *ratione materiae* គេត្រូវតែបំពេញលក្ខខណ្ឌដែលថា "មានក្របខ័ណ្ឌច្បាប់គ្រប់គ្រាន់ ដែលអាចផ្ដន្ទាទោសចំពោះទង្វើរបស់ជនជាប់ចោទ ហើយប្រសិនបើរកឃើញថាមានពិរុទ្ធភាព ការផ្ដន្ទាទោសដ៏សមស្របមួយគួរត្រូវបានយកមកអនុវត្ត ដោយយោងទៅលើបទល្មើសដែលកំពុងចោទប្រកាន់នៅចំពោះមុខអង្គជំនុំជម្រះនេះ"[63]។ ទាំងគូភាគីក្ដី ទាំងប្រទេសណ័រវេយ បានសំអាងទៅលើគោលការណ៍នៃយុត្តាធិការជាសកល (the principle of universal jurisdiction) ដើម្បីបង្កើតយុត្តាធិការ។ ទាក់ទិនទៅនឹងបញ្ហានេះ អង្គជំនុំជម្រះបានលើកឡើងថា សញ្ញាណនៃយុត្តាធិការជាសកលអាចអនុវត្តបានចំពោះតែការបង្កើតយុត្តាធិការទៅលើ *ratione loci*[64] (មានន័យថា ដោយសារមូលហេតុនៃទីកន្លែង)[65] គឺមិនមែនចំពោះយុត្តាធិការ

---

[61] *រឿងក្ដីរដ្ឋអាជ្ញា តទល់. Bagaragaza*, ICTR-2005-86-R11*ស្ទួន*, សេចក្ដីសម្រេចលើញត្តិអយ្យការ សម្រាប់ការយោងទៅនឹងរាជាណាចក្រ Norway – វិធាន១១*ស្ទួន* នៃវិធាននីតិវិធី និងភស្តុតាង ចុះថ្ងៃទី១៩ ខែឧសភា ឆ្នាំ២00៦។

[62] *ដូចជើងទំព័រខាងលើ*, កថាខណ្ឌ ១៦។

[63] *ដូចជើងទំព័រខាងលើ*, កថាខណ្ឌ ១២។ *សូមមើលផងដែរ រឿងក្ដីរដ្ឋអាជ្ញា តទល់ Stanković*, IT-96-23/2-PT, សេចក្ដីសម្រេចលើការយោងទៅនឹងករណីក្រោមវិធាន ១១*ស្ទួន* ចុះថ្ងៃទី១៧ ខែឧសភា ឆ្នាំ២00៥, កថាខណ្ឌ៣២ "ប្រសិនបើករណីនេះនឹងត្រូវយោងទៅ Bosnia និង Herzegovina នឹងមានគ្រោងច្បាប់គ្រប់គ្រាន់ ដែលផ្លាស់ជារឿងឧក្រិដ្ឋនូវអំពើដែលត្រូវបានចោទប្រកាន់របស់ជនជាប់ចោទ ដើម្បីការចោទប្រកាន់អាចត្រូវបានកាត់សេចក្ដី និងកំណត់ដោយត្រឹមត្រូវ និងដែលកំណត់សម្រាប់ការផ្ដន្ទាទោស។ ដូច្នេះ ចៅក្រមជំនុំជម្រះត្រូវពិចារណាថាតើច្បាប់ ដែលអាចអនុវត្តបានក្នុងដំណើរការនីតិវិធីមុខតុលាការរដ្ឋ នឹងអនុញ្ញាតការកាត់សេចក្ដី និងការជំនុំជម្រះរបស់ជនជាប់ចោទ ហើយប្រសិនបើរកឃើញថាមានកំហុស ការផ្ដន្ទាទោសសមរម្យនៃជនជាប់ចោទ សម្រាប់បទល្មើសនៃប្រភេទដែលគាត់កំពុងត្រូវបានចោទប្រកាន់នៅចំពោះមុខអង្គជំនុំជម្រះ"។

[64] សេចក្ដីសម្រេច *Bagaragaz* , កថាខណ្ឌ១៣, ជើងទំព័រ១១។

[65] វចនានុក្រម BLACK'S LAW DICTIONARY 1269 (West Publishing Co, ប្រែសម្រួលលើកទី៧ ឆ្នាំ១៩៩៩)

ទៅលើ *ratione materiae* នោះទេ (មានន័យថា ដោយសារមូលហេតុនៃបញ្ហាពាក់ព័ន្ធ)[66]។ អង្គជំនុំជម្រះបានពិចារណាថា ការដែលច្បាប់ព្រហ្មទណ្ឌប្រទេសណ័រវេយមិនបានធ្វើការផ្តន្ទាទោសឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ មានន័យថា អនុសញ្ញាប្រឆាំងនឹងអំពើប្រល័យពូជសាសន៍នេះ មិនត្រូវបានដាក់បញ្ចូលទៅក្នុងច្បាប់ជាតិរបស់ប្រទេសនេះទេ។ អាស្រ័យហេតុនេះ ប្រទេសណ័រវេយមិនអាចប្រើប្រាស់អនុសញ្ញានេះជាមូលដ្ឋានសម្រាប់ការផ្តន្ទាទោសបានឡើយ[67]។ ជាផលវិបាក អំពើដែលត្រូវបានចោទប្រកាន់ចំពោះជនជាប់ចោទមិនអាចផ្តល់លក្ខណៈសម្បត្តិផ្លូវច្បាប់ឱ្យបានពេញលេញនៅក្រោមច្បាប់ព្រហ្មទណ្ឌនៃប្រទេសណ័រវេយ ហើយលក្ខខណ្ឌតម្រូវសម្រាប់យុត្តាធិការត្រូវបានពិចារណាថា មិនបានបំពេញនោះឡើយ។[68]

៣៤. អាស្រ័យហេតុនេះ ទោះបីជាអំពើប្រល័យពូជសាសន៍ត្រូវបានចាត់ទុកថាជាឧក្រិដ្ឋកម្មដែលទទួលបានឋានៈជា *វិធានអាជ្ញាបញ្ញា* (*jus cogens*) ក៏ដោយ ក៏ឋានៈនេះតម្រូវឱ្យរដ្ឋទាំងឡាយមិនចូលពាក់ព័ន្ធនៅក្នុងអំពើប្រល័យពូជសាសន៍នោះទេ ក៏ប៉ុន្តែ មិនតម្រូវជាចាំបាច់ឱ្យរដ្ឋទាំងឡាយធ្វើការផ្តន្ទាទោសចំពោះឧក្រិដ្ឋកម្មនេះទេ។ បណ្តារដ្ឋទាំងឡាយមិនអាចសំអាងចរិតលក្ខណៈជា *វិធានអាជ្ញាបញ្ញា* (*jus cogens*) នៃឧក្រិដ្ឋកម្មនេះដើម្បីអនុវត្តយុត្តាធិការខាងលើនេះបានទេ លុះត្រាណាតែប្រព័ន្ធច្បាប់ជាតិរបស់ខ្លួនបានចែងអោយមានយុត្តាធិការនេះ។ ប្រព័ន្ធច្បាប់កម្ពុជាមិនបានចែងអោយមានបែបនេះទេ។

## III. សំណូមពរ

**អាស្រ័យទៅលើ** ហេតុផលដូចបានលើកឡើងនៅក្នុងសារណានេះ មេធាវីការពារក្តីសូមសំណូមពរដល់សហចៅក្រមស៊ើបអង្កេតមេត្តា **បដិសេធចោល**ការយកច្បាប់ស្តីពីឧក្រិដ្ឋកម្មប្រល័យពូជសាសន៍មកអនុវត្តនៅចំពោះមុខ អវតក ។

---

[66] *ដូចជើងទំព័រខាងលើ*

[67] សេចក្តីសម្រេច *Bagaragaza* កថាខណ្ឌ ១៣ លេខយោងទី ១១ ។

[68] *ដូចជើងទំព័រខាងលើ*, កថាខណ្ឌ១៦។

ឯកសារៈ D240

០០២/១៩-០៩-២០០៧-អ.វ.ត.ក-ក.ស.ច.ស

សូមសហចៅក្រមស៊ើបអង្កេតទទួលយកសំណើសុំនេះដោយក្តីគោរព។

**ធ្វើនៅភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ថ្ងៃទី ៣០ ខែតុលា ឆ្នាំ ២០០៩**

មេធាវី
AVOCAT
ATTORNEY
AT LAW
KINGDOM OF CAMBODIA

**អាង ឧត្តម** **Michael G. KARNAVAS**

សហមេធាវីរបស់លោក **អៀង សារី**